CEDAC

# កសិករ និង ធម្មជាតិ

# *Farmer and Nature*

## កម្រងសៀវភៅសំរាប់អភិវឌ្ឍន៍កសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា

# បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ



រៀបរៀងដោយៈ លោក រាជ សុភាព

សេដាក ២០១២

**បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ**

បោះពុម្ពផ្សាយដោយ : មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ( សេដាក)

រៀបរាងដោយ : រាជ សុភាព

រក្សាសិទ្ធិដោយ : អង្គការ សេដាក

បោះពុម្ពដោយ :    រោងពុម្ព ឥន្ទ្រីយ៍មាស

# សេចក្តីថ្លែងអំណរគុណ

សៀវភៅស្តីអំពី " **បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ** " បានកើតឡើងជារូបរាងដោយឈរលើ មូលដ្ឋាននៃការចុះសិក្សា និងបទពិសោធន៍ចិញ្ចឹមត្រីជាមួយកសិករកន្លងមក នៅខេត្តតាកែវ កំពង់ចាម កំពង់ឆ្នាំង និង ស្វាយរៀង ។ ខ្ញុំចងក្រងជាសៀវភៅនេះ ក្នុងគោលបំណងដើម្បីជួយបំភ្លឺបន្ថែមនូវ បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារដល់កសិករដែលមិនទាន់ទទួលបច្ចេកទេសបានទូលំទូលាយ និងជួយផ្តល់យោបល់បន្ថែមដែលជាមូលដ្ឋានគ្រឹះក្នុងការចិញ្ចឹមត្រីរបស់ខ្លួនអោយបានទទួលផលខ្ពស់ជាងមុន។ ខ្ញុំព្យាយាមធ្វើយ៉ាងណាអោយសៀវភៅនេះមានលក្ខណៈសាមញ្ញ ដើម្បីអោយកសិករងាយយល់ និងអាចអនុវត្តបានក្នុងការចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ ។

ខ្ញុំសូមថ្លែងអំណរគុណដល់កសិករដែលមានបទពិសោធន៍ចិញ្ចឹមត្រីកន្លងមកបានចូលរួមផ្តល់យោបល់ និងបទពិសោធន៍ចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ ដូចជា កសិករ នាក់ ហ៊ីម រស់ មៅ កែវ ប៊ុន ចាន់ សុធា សយ សុធា សុខ មុំ និង អ៊ុំ ធី ( នៅខេត្តតាកែវ ) កសិករ ឡាយ សាបូ ណូប ស៊ីម៉ុន ជា តិច គង់ មឿង សៀម អិត (នៅខេត្ត ព្រៃវែង) និង កសិករ រាជ ឆាន សុខ ទិត្យ ភេ សារ៉ែន និង ពេជ្រ ផល្លា (នៅខេត្តស្វាយរៀង) ។

ទន្ទឹមនឹងនេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់បុគ្គលិកសេដាកទាំងអស់ដែលបានចូលរួមចំណែកនូវគំនិតកែលំអសៀវភៅនេះ ជាពិសេស លោក ម៉ា វាសនា ហួត ស៊ីណាត ហ៊ីវ សារ៉ុន ធៀម សុផល អ៊ុយ ថុល ឡាំ ឌឿន ប៉ែន ប៊ុនធឿន ជា ផល្លា លីម សូវៀត កញ្ញ ម៉ុក ចិន្តា និងអ្នកស្រី ស៊ិន អង្គារសាធ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ បណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការសេដាក និង អ្នកស្រី ពាន សុខា ដែលបានចូលរួមចំណែកក្នុងការជួយនិពន្ធកែលំអ និងជំរុញអោយសៀវភៅនេះចេញជារូបរាងឡើងសំរាប់កសិករ ។

សូមថ្លែងអំណរគុណដល់គំរោងកែលំអកំរិតជីវភាពរបស់កសិករក្រីក្រ នៅភាគខាងត្បូងប្រទេសកម្ពុជា **(JFPR)** គំរោងប្រព័ន្ធចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពសំរាប់គ្រួសារកសិករក្រីក្រ **(SRL)** គំរោងកែលំអជីវភាពគ្រួសារកសិករស្រុកត្រាំកក់ និង កំពង់ត្រឡាច **(ILFARM Tramkak, IIFARM Kampong Tralach)** ដែលបានជួយឧបត្ថម្ភថវិកាក្នុងការបោះពុម្ពសៀវភៅនេះ ។

ខ្ញុំយល់ថា សៀវភៅនេះនៅមានចំនុចខ្វះខាតជាច្រើន ទាំងខ្លឹមសារ និងរូបភាព។ ខ្ញុំសប្បាយរីករាយនូវការជួយកែលំអពីសំណាក់អ្នកអាន និងអ្នកអនុវត្តន៍ផ្ទាល់ ឬ អ្នកមានចំណាប់អារម្មណ៍ផ្សេងៗ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទុកជាមុនចំពោះការចូលរួមចំណែកដ៏មានតំលៃនេះ ។

អ្នកនិពន្ធ

**រាជ សុភាព**

ម.ព.ឯ.ក AIDOC
Code: 142-035
Date: i
Donated by:

# មាតិកាអត្ថបទ


សេចក្តីថ្លែងអំណរគុណ ទំព័រ

សេចក្តីផ្តើម ........ ១

១. ហេតុអ្វីបានជាយើងចាំបាច់ចិញ្ចឹមត្រី ? ........ ២

២. ចរិតរស់នៅនៃប្រភេទត្រីចិញ្ចឹមមួយចំនួន ........ ៣

២.១.ប្រភេទត្រីក្រៅស្រុក ........ ៣

២.២.ប្រភេទត្រីក្នុងស្រុក........ ៧

៣. ការរៀបចំកន្លែងចិញ្ចឹមត្រី........ ១០

៣.១. ជ្រើសរើសទីតាំងជីកស្រះ ឬ ប្រឡាយ ........ ១០

៣.២. របៀបជីកស្រះ ........ ១១

៣.៣. របៀបរៀបចំស្រះ ឬ ប្រឡាយថ្មី ........ ១២

៣.៤. របៀបរៀបចំ ស្រះ ឬ ប្រឡាយចាស់........ ១៣

៤. ប្រភពទឹក ........ ១៦

៥. របៀបកៀរចាប់ វេចខ្ចប់ ដឹកជញ្ជូន និងលែងកូនត្រី........ ១៧

៥.១. របៀបបង្វឹកកូនត្រី........ ១៧

៥.២. របៀបវេចខ្ចប់កូនត្រីដោយបិទជិត ( ថង់ប្លាស្ទិក) ........ ១៥

៥.៣. ដឹកជញ្ជូនកូនត្រីដោយចំហ ( ធុងជ័រ ប៉ោត កានជ័រ) ........ ២១

៥.៤. របៀបលែងកូនត្រី ........ ២១

៥.៥. ប្រភេទត្រី ប្រវែងដងខ្លួនកូនត្រី និង ចំនួនកូនត្រីដាក់ចិញ្ចឹម ........ ២២

៦. ប្រភេទចំណីត្រី........ ២៣

៧. ការគ្រប់គ្រង និងថែទាំត្រី ........ ២៧

៨. វិធីការពារ និងព្យាបាលជំងឺត្រី ........ ៣២

៩. ការប្រមូលផលត្រី........ ៣៤

១០. បទពិសោធន៍សំខាន់ៗ របស់កសិករក្នុងការចិញ្ចឹមត្រី ........ ៣៥

១១. ការសរុបនូវចំណុចសំខាន់ៗ និង សំណូមពរ ........ ៣៩

ឧបសម្ព័ន្ធ

ឯកសារយោង

# បញ្ជីរូបភាព


រូបភាព ១ : ធនធាន និងកត្តាជាមូលដ្ឋានក្នុងការចិញ្ចឹមត្រី ............................ ២
រូបភាព ២ : ត្រីកាបស ............................................ ៣
រូបភាព ៣ : ត្រីកាបក្បាលធំ ............................................ ៤
រូបភាព ៤ : ត្រីកាបសាមញ្ញ ............................................ ៤
រូបភាព ៥ : ត្រីកាបឥណ្ឌា ............................................ ៥
រូបភាព ៦ : ត្រីទីឡាព្យ៉ា ............................................ ៦
រូបភាព ៧ : ត្រីហឿងក្រហម ............................................ ៦
រូបភាព ៨ : ត្រីឆ្ពិន............................................ ៧
រូបភាព ៩ : ត្រីកន្ធរ ............................................ ៨
រូបភាព ១០ : ត្រីព្រលូង ............................................ ៨
រូបភាព ១១ : ត្រីប្រា............................................ ៩
រូបភាព ១២ : ត្រីអណ្ដែង............................................ ១០
រូបភាព ១៣ : ស្រះចិញ្ចឹមត្រីនៅទីកន្លែងស្រឡះ ............................ ១១
រូបភាព ១៤ : ពិនិត្យគុណភាពដី ដើម្បីជីកស្រះ ............................ ១១
រូបភាព ១៥ : គំនូសកាត់ទទឹងស្រះ ( មើលពីចំហៀងស្រះ) ............................ ១២
រូបភាព ១៦ : ជើងទេរនៃស្រះ និងជំរាលមួយចំហៀង ............................ ១២
រូបភាព ១៧ : ដាក់ជីអាចម៍សត្វស្ងួត ( គោ+មាន់) និង រុក្ខជាតិស្រស់ ............................ ១៣
រូបភាព ១៨ : ទុកដីភក់ (ដីចាស់) នៅបាតស្រះ............................ ១៤
រូបភាព ១៩ : បាចកំបោរស រួចហាលថ្ងៃបាតស្រះ............................ ១៤
រូបភាព ២០ : យើងលែងកូនត្រី នៅពេលឃើញទឹកស្រះមានបណ្ដូលចេក ............................ ១៥
រូបភាព ២១ : របៀបពិនិត្យគុណភាពទឹកស្រះ ............................ ១៦
រូបភាព ២២ : ពន្លិចអួនអោយកូនត្រីហែលចេញពីក្នុងអួន ............................ ១៨
រូបភាព ២៣ : បន្សាំកូនត្រីក្នុងហាប៉ាមុនពេលដឹកជញ្ជូន ( រយៈពេលតិចបំផុត ២៤ ម៉ោង) ............ ១៨
រូបភាព ២៤ : របៀបរាប់កូនត្រីដាក់ក្នុងថង់............................ ១៩
រូបភាព ២៥ : ដាក់សំបកបាវស៊ីម៉ង់ត៍ពីខាងក្រៅ និងថង់ដាក់កូនត្រីខាងក្នុង ............................ ១៩
រូបភាព ២៦ : បញ្ចូលខ្យល់អុកស៊ីហ្សែនក្នុងថង់ដាក់កូនត្រី ............................ ២០
រូបភាព ២៧ : ដាក់កូនត្រីក្នុងកានជ័រ ឬ ប៉ោត ............................ ២១
រូបភាព ២៨ : ត្រាំថង់កូនត្រី និងបំប៉នក្នុងហាប៉ា............................ ២១
រូបភាព ២៩ : លែងកូនត្រីចូលក្នុងស្រះ ............................ ២២
រូបភាព ៣០ : ប្រវែងកូនត្រីលែងចូលក្នុងស្រះ ............................ ២៣
រូបភាព ៣១ : ប្រភេទចំណីធម្មជាតិ ............................ ២៣
រូបភាព ៣២ : ស្នោរចំណីអោយត្រីស៊ី ............................ ២៤
រូបភាព ៣៣ : ពិនិត្យចំណី និងបរិមាណត្រីនៅក្នុងកញ្ច្រែងដាក់ចំណី ............................ ២៥

រូបភាព ៣៤ : ស៊ុមដាក់ចំណីត្រី ........................................ ២៦
រូបភាព ៣៥ : ត្រួតពិនិត្យការលូតលាស់របស់ត្រី ពេលដាក់ចំណី ........................ ២៦
រូបភាព ៣៦ : ការផ្តល់ចំណីបន្ថែម និងចិញ្ចឹមត្រីក្នុងស្រះភ្ជាប់ទៅនឹងស្រែ........................ ២៧
រូបភាព ៣៧ : មុនពេលដាក់ចំណី យើងត្រូវគោះទឹកជាសញ្ញា ដើម្បីអោយត្រីមករកស៊ីចំណី........... ២៨
រូបភាព ៣៨ : ស៊ុមដាក់ចំណី ( ដាក់ចកនៅ ១ ចំហៀងស្រះ) ........................ ២៨
រូបភាព ៣៩ : សំអាតរុក្ខជាតិដុះក្នុងស្រះចិញ្ចឹមត្រី ..............................២៩
រូបភាព ៤០ : បន្ថែមទឹកចូលស្រះច្រោះដោយស្បៃមុងកុំអោយត្រីស្រែចូល ........................ ៣០
រូបភាព ៤១ : ពពួកសត្វស៊ីកូនត្រី ........................................ ៣០
រូបភាព ៤២ : ទន្រ្ទានខែត្រ និងសណ្តែកអង្រែពន្លិចក្នុងទឹកស្រះ........................ ៣១
រូបភាព ៤៣ : ប្រើសំណាញ់ចាប់ត្រី ដើម្បីត្រួតពិនិត្យការលូតលាស់របស់ត្រី ........................ ៣២
រូបភាព ៤៤ : កូនត្រីកើតជំងឺ (មេរោគស៊ីនៅគល់កន្ទុយត្រី)........................ ៣៣
រូបភាព ៤៥ : សត្វយុក្កា ........................................ ៣៣
រូបភាព ៤៦ : សត្វចៃត្រី ........................................ ៣៣
រូបភាព ៤៧ : ការប្រមូលយកត្រីធំ និង បំប៉នត្រីតូចបន្ត ........................ ៣៤
រូបភាព ៤៨ : ការប្រមូលផលត្រី ........................................ ៣៤

## បញ្ជីតារាង

តារាង ១ : បរិមាណចំណីផ្តល់អោយស៊ីក្នុង ១ ថ្ងៃ (គិតជាភាគរយ) នៃទំងន់ខ្លួនត្រីសរុបក្នុងស្រះ ..... ២៤
តារាង ២ : របៀបគណនាបរិមាណចំណីផ្តល់អោយត្រីស៊ីក្នុង ១ ថ្ងៃ ........................ ២៥

## <u>កំណត់សំគាល់:</u>

ម : អក្សរសរសេរកាត់ អានថា *ម៉ែត្រ*

ស.ម : អក្សរសរសេរកាត់ អានថា *សង្ទីម៉ែត្រ*

គ.ក្រ : អក្សរសរសេរកាត់ អានថា *គីឡូក្រាម*

ម២ : អក្សរសរសេរកាត់ អានថា *ម៉ែត្រក្រឡា ឬ ម៉ែត្រការ៉េ ( ១ ម៉ែត្របួនជ្រុង)*

៥ × ៧ / ១០០ : អក្សរសរសេរកាត់ អានថា *៥ គុណ ៧ ចែកនឹង ១០០*

/ : សញ្ញានេះមានន័យថា *ក្នុង ១* (ឧទាហរណ៍: ផ្តល់ចំណីអោយត្រីស៊ី ២ ដង ក្នុង ១ ថ្ងៃ)

, : សញ្ញានេះមានន័យថា *ក្បៀស* ( ឧទាហរណ៍: ជំរៅទឹក ០,៥ ម៉ែត្រ)

## <u>ខ្នាតដែលកសិករធំលាប់ប្រើ:</u>

| | | |
|---|---|---|
| ១ លី = ១ មីលីម៉ែត្រ | ១ ហ៊ុន = ១ សង្ទីម៉ែត្រ | ១ តឹក = ១០ សង្ទីម៉ែត្រ |
| ១ អារ = ១០០ ម៉ែត្រការ៉េ | ១០០ អារ = ១ ហិកតា = ១០.០០០ ម៉ែត្រការ៉េ | |
| ១០០ សង្ទីម៉ែត្រ = ១ ម៉ែត្រ | ១ ខាំ = ១០០ ក្រាម | ១.០០០ ក្រាម = ១ គីឡូក្រាម |

## <u>ពន្យល់ន័យ:</u>

- *<u>ម៉ែត្រការ៉េ:</u>* មួយម៉ែត្របួនជ្រុង ។
- *<u>ប្លង់តុង:</u>* គឺ ជាពពួកសត្វ ឬ រុក្ខជាតិល្អិតៗដែលរស់នៅក្នុងទឹក ។
- *<u>សត្វប្លង់តុង និងរុក្ខជាតិប្លង់តុង (ឬ ចំណីធម្មជាតិ):</u>* វាកើតឡើងក្រោយពេលដាក់ជីលាមកសត្វ និងរុក្ខជាតិ ក្រោយបញ្ចូលទឹកបាន រយៈពេលពី ៤ ទៅ ៧ ថ្ងៃ) ។
- *<u>បាចកំបោរស (កំបោរលាបរបងផ្ទះ ឬ ជញ្ជាំងផ្ទះ):</u>* បាចកំបោរក្រោយពេលពង្រីងស្រះ (ភក់នៅសើម) ។
- *<u>កំបោរសមានគុណភាព</u>*: គឺប្រភេទកំបោរដែលរាយ( ផុស)ហើយដាក់ចូលក្នុងទឹកវាមានប្រតិកម្មភ្លាម (ពុះ) ។
- *<u>ត្រីពុល</u>* : នៅពេលអាកាសធាតុមេឃហាប់ និងមេឃក្តៅហើយភ្លៀង រួមទាំងទឹកស្រះខ្វះអុកស៊ីហ្សែន និងបរិមាណត្រីក្នុងស្រះច្រើនពេក ។ ក្រៅពីនេះ បង្កឡើងដោយសារការបង្ហូរសារធាតុគីមី ឬ ថ្នាំពុល កាកសំណល់ពីរោងចក្រ សហគ្រាស ឬទីប្រជុំជនចូលក្នុងបរិស្ថានទឹកដែលមកប្រើក្នុងការចិញ្ចឹមត្រី ។ នៅតាមជនបទ កសិករដាក់អាចម៍សត្វស្រស់ និងរុក្ខជាតិលើសចំនួន ។
- *<u>ចំណីផ្សំ:</u>* ជាចំណីដែលផ្សំរួមមាន ដូចជា កន្ទក់ ម្សៅពោត ចុងអង្ករ ម្សៅដំឡូង ត្រីជី ( ត្រីមិនអាចកែច្នៃធ្វើម្ហូប) ឬ ម្សៅត្រី ។ល ។
- *<u>ប្រភេទត្រីក្រៅស្រុក:</u>* ជាប្រភេទត្រីនាំចូលពីប្រទេសខាងក្រៅមកចូលក្នុងស្រុក ( ពូជក្រៅស្រុក) ។
- *<u>ប្រភេទត្រីក្នុងស្រុក:</u>* ជាប្រភេទត្រីដែលមានដើមកំនើតកកើតក្នុងស្រុកជាយូរមកហើយ ( ពូជក្នុងស្រុក) ។
- *<u>ស៊ីចំណីចំរុះ:</u>* ស៊ីចំណីទាំងជាតិសាច់ រុក្ខជាតិ កាកសំណល់ផ្ទះបាយ ចំណីផ្សំ អាចម៍សត្វ ចំណីគ្រាប់ ។
- *<u>ស្រះថ្មី:</u>* ស្រះទើបនឹងជីករួច មិនទាន់ស្តុកទឹកបានមួយរដូវវស្សា ។
- *<u>ហាលបាតស្រះ:</u>* ពង្រីងទឹកអោយរីងពីបាតស្រះ រួចបាចកំបោរស ហើយទុកចោលដោយមិនអោយទឹកខាងក្រៅហូរចូលក្នុងស្រះ។ បាចកំបោរសនៅពេលថ្ងៃក្តៅ ( មេឃគ្មានភ្លៀង) ។
- *<u>ហាប៉ា ( ស្បៃមុង):</u>* មុងសំរាប់ដាក់កូនត្រី ដែលធ្វើពីសាច់ក្រណាត់ ឬ សាច់ស្បៃមុង ។
- *<u>ពពួកបារ៉ាសិត:</u>* ជាភ្នាក់ងារចំលងជំងឺ វាខាំតោងជាប់នឹងខ្លួនត្រី ។
- *<u>ពណ៌ទឹកមានគុណភាព:</u>* ទឹកមានគុណភាពមានពណ៌ត្រួយចេក ឬ ពណ៌សំបកសណ្តែកខៀវ ។

## រូបមន្តសំខាន់ៗដែលអ្នកចិញ្ចឹមត្រីគួរយកចិត្តទុកដាក់

| |
|---|
| ក្រលាផ្ទៃស្រះ ( $ម^{២}$ ) = ប្រវែងបណ្តោយស្រះ ( ម) × ប្រវែងទទឹងស្រះ ( ម) |

**ឧទាហរណ៍:** ស្រះមានបណ្តោយប្រវែង ២០ ម៉ែត្រ និងទទឹងប្រវែង ១០ ម៉ែត្រ។ ស្រះរាងចតុកោណកែង។

ក្រលាផ្ទៃស្រះ = ២០ ម x ១០ ម = ២០០ $ម^{២}$

| |
|---|
| **បរិមាណកំបោរសប្រើ ( គ.ក្រ)** = **ផ្ទៃក្រលាស្រះ ( $ម^{២}$ )** x **បរិមាណកំបោរសប្រើក្នុងស្រះ ១០០ $ម^{២}$** |

**ឧទាហរណ៍:** ផ្ទៃក្រលាស្រះមាន ២០០ $ម^{២}$ ។ គេបាចកំបោរស ១០ គ.ក្រ ក្នុងស្រះ ១០០ $ម^{២}$ ។

$$បរិមាណកំបោរស ( គ.ក្រ) = \frac{២០០\ ម^{២}\ X\ ១០\ គ.ក្រ}{១០០\ ម^{២}} = ២០\ គ.ក្រ$$

| |
|---|
| **បរិមាណអាចម៍ក្របី ( គ.ក្រ)** = ផ្ទៃក្រលាស្រះ ( $ម^{២}$ ) x បរិមាណអាចម៍ក្របីប្រើក្នុងស្រះ ១០០ $ម^{២}$ |

**ឧទាហរណ៍:** ផ្ទៃក្រលាស្រះ ២០០ $ម^{២}$ ។ គេដាក់អាចម៍គោ ឬ អាចម៍ក្របីស្ងួត ៤០ គ.ក្រ ក្នុងស្រះ ១០០ $ម^{២}$ ។

$$បរិមាណអាចម៍គោ\ ឬ\ អាចម៍ក្របីស្ងួត ( គ.ក្រ) = \frac{២០០\ ម^{២}\ X\ ៤០\ គ.ក្រ}{១០០\ ម^{២}} = ៨០\ គ.ក្រ$$

| |
|---|
| **បរិមាណកូនត្រីលែងចូលក្នុងស្រះ ( ក្បាល)** = ផ្ទៃក្រលាស្រះ x បរិមាណកូនត្រីលែងចូលស្រះ ក្នុង ១$ម^{២}$ |

**ឧទាហរណ៍:** ផ្ទៃក្រលាស្រះ ២០០ $ម^{២}$ ។ គេលែងកូនត្រីចូលក្នុងស្រះ ចំនួន ៣កូនត្រី ក្នុង ១ $ម^{២}$ នៃផ្ទៃស្រះ។

| |
|---|
| ចំនួនកូនត្រីលែងចូលក្នុងស្រះ ( ក្បាល) = ២០០ $ម^{២}$ X ៣ ក្បាល = ៦០០ ក្បាល |

| |
|---|
| **បរិមាណចំណីអោយស៊ីក្នុង ១ ថ្ងៃ** = ទំងន់ត្រីសរុបក្នុងស្រះ x អោយស៊ី ៣ ភាយរយ នៃទំងន់ត្រីសរុប |

**ឧទាហរណ៍:** ត្រីចិញ្ចឹមក្នុងស្រះមានចំនួន ៣០០ ក្បាល។ ត្រី ១ ក្បាល មានទំងន់ជាមធ្យម ៣ ខាំ ( ០,៣ គ.ក្រ) ។ គេផ្តល់ចំណីអោយស៊ី ៣ ភាគរយ នៃទំងន់ត្រីសរុបក្នុងស្រះ។

$$បរិមាណចំណីអោយស៊ីក្នុង\ ១\ ថ្ងៃ ( គ.ក្រ) = \frac{( ៣០០\ ក្បាល\ X\ ០,៣\ គ.ក្រ )\ X\ ៣}{១០០} = ២,៧\ គ.ក្រ$$

## សេចក្តីផ្តើម

សាច់ត្រីជាប្រភពម្ហូបអាហារមានជីវជាតិខ្ពស់ ជាពិសេសជាតិប្រូតេអ៊ីនដែលជួយដល់ការលូតលាស់សរីរាង្គកាយរបស់មនុស្ស សត្វ និងមានសារៈសំខាន់បំផុតសំរាប់ជួយដល់ម្ហូបអាហារប្រចាំថ្ងៃ។ បច្ចុប្បន្ននេះ បរិមាណត្រីនៅក្នុងធម្មជាតិផ្គត់ផ្គង់មិនគ្រប់គ្រាន់ ដោយសារបំរែបំរួលនៃធម្មជាតិផ្គួបផ្សំជាមួយការគំរាមកំហែងពីមនុស្ស ដូចជា ការប្រើថ្នាំពុល ជីគីមី ការប្រើឧបករណ៍នេសាទហាមឃាត់ និងការកើនឡើងជាលំដាប់ពីកំណើនមនុស្ស។ ក្រៅពី ផលនេសាទត្រីទឹកសាប និងទឹកប្រៃ គឺមានតែការចិញ្ចឹមត្រីបន្ថែមទៀត ទើបអាចកាត់បន្ថយនូវសំពាធនៃការនេសាទត្រីធម្មជាតិ និងជួយបំពេញនូវតំរូវការហូបចុកដល់មនុស្ស។

ដើម្បីចូលរួមចំណែកក្នុងការលើកកំពស់កំរិតជីវភាព ជាពិសេសម្ហូបអាហារប្រចាំថ្ងៃរបស់កសិករ ខ្ញុំបានប្រមូលផ្តុំ នូវបច្ចេកទេស និងការដកស្រង់បទពិសោធន៍ល្អៗពីអ្នកចិញ្ចឹមត្រីយកមកចងក្រងជាសៀវភៅ ដែលមានឈ្មោះថា:

# "បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈគ្រួសារ"

សៀវភៅនេះ អាចជំនួយដល់កសិករពីការចិញ្ចឹមត្រី។ ការណែនាំក្នុងសៀវភៅនេះ ផ្តោតទៅលើរបៀបសាមញ្ញៗ ដូចជា ជ្រើសរើសទីកន្លែងចិញ្ចឹម ការរៀបចំស្រះ ចរិតរស់នៅនៃប្រភេទត្រីចិញ្ចឹមមួយចំនួន ពេលវេលានៃការដាក់កូនត្រីចិញ្ចឹម ប្រភេទចំណីអោយស៊ី របៀបផ្សំចំណី ការគ្រប់គ្រង និងការថែទាំត្រី របៀបការពារ និងព្យាបាលជំងឺត្រី។

ខ្លឹមសារក្នុងសៀវភៅនេះនឹងជួយណែនាំបង្ហាញប្រាប់ពីមូលដ្ឋានគ្រឹះសំខាន់ៗ និងជួយបំភ្លឺផ្លូវដែលអ្នកបានជួបនូវបញ្ហាក្នុងការចិញ្ចឹមត្រី ហើយអាចជួយកែនូវចំនុចខ្វះខាតណាមួយ ដើម្បីអោយទិន្នផលត្រីបានខ្ពស់ជាងមុន។

## ១. ហេតុអ្វីបានជាយើងចាំបាច់ចិញ្ចឹមត្រី ?

កសិករខ្មែរយើងភាគច្រើនមានទំលាប់ជីកស្រះយកដីដាក់ភូមិ ឬ សួនបន្លែ រីឯស្រះរក្សាទឹកសំរាប់ប្រើប្រាស់ក្នុងគ្រួសារ និងនៅចុងរដូវប្រាំង គេអាចប្រមូលផលត្រីធម្មជាតិបានពីស្រះថែមទៀតផង។ ក្រោយមកដោយមានការគំរាមកំហែងពីមនុស្ស និងការប្រែប្រួលធម្មជាតិបានធ្វើអោយការប្រមូលផលត្រីធម្មជាតិថយចុះ។ ឥឡូវនេះ យើងគួរធ្វើការគិតដល់របៀបចិញ្ចឹមត្រី ដូចជា រៀបចំសំអាតស្រះ ផ្តល់ចំណី បន្ថែមពូជត្រី និងបង្កើតបរិស្ថានល្អដល់ជំរកត្រី ដើម្បីអោយត្រីមានការលូតលាស់ និងធំធាត់លឿន។ ការចិញ្ចឹមត្រីនាំមកនូវផលប្រយោជន៍ជាច្រើនដល់កសិករដូចជា:

- ដោះស្រាយសាច់ត្រីធ្វើជាម្ហូបបានទាន់ចិត្ត
- បង្កើនប្រាក់ចំណូលក្នុងគ្រួសារ ដោយមិនចំណាយថវិកាទិញត្រីពីទីផ្សារ
- កាត់បន្ថយការនេសាទត្រីធម្មជាតិបានមួយកំរិត
- បង្កើតការងារអោយសមាជិកក្នុងគ្រួសារ
- បង្កើនសួនបន្លែក្នុងការដាំដុះ តាមរយៈការពង្រីក និងស្តារស្រះចិញ្ចឹមត្រី
- ប្រើប្រាស់កាកសំណល់ផ្ទះបាយ ដូចជា បន្លែ បាយ អាចយកមកប្រើជាចំណីត្រីបាន ។

ដើម្បីចិញ្ចឹមត្រីអោយបានផលល្អ ទាមទារអោយយើងមានការយល់ដឹងពីគោលការណ៍ និងបច្ចេកទេសសំខាន់ៗមួយចំនួន ដូចជា ការជ្រើសរើសទីកន្លែងចិញ្ចឹម ការស្គាល់ពីចរិតរបស់ត្រី ការគ្រប់គ្រងគុណភាពទឹកស្រះ ការផ្តល់ចំណី ការថែទាំ និងគ្រប់គ្រង ការការពារ និងព្យាបាលជំងឺត្រី ។

ការចិញ្ចឹមត្រីគឺពឹងផ្អែកលើធនធាន និងកត្តាជាមូលដ្ឋានគ្រឹះមួយចំនួន។ ដូច្នេះ ដើម្បីទទួលបានផលត្រីល្អ អ្នកចិញ្ចឹមត្រីគប្បីស្វែងយល់នូវចំនុចមួយចំនួនដូច ខាងក្រោម:




**រូបភាព ១ : ធនធាន និងកត្តាជាមូលដ្ឋានក្នុងការចិញ្ចឹមត្រី**

## ២. ចរិតរស់នៅនៃប្រភេទត្រីចិញ្ចឹមមួយចំនួន

ការចិញ្ចឹមត្រីក្នុងស្រះ ឬ ប្រឡាយ គប្បីជ្រើសរើសប្រភេទត្រីណាដែលសំខាន់ជាងគេក្នុងបណ្តាប្រភេទត្រីដាក់ចិញ្ចឹមជាពិសេសជ្រើសរើសប្រភេទត្រីដែលចរិតរស់នៅស៊ីចំណីចំរុះ ជាពិសេសងាយស្រួលក្នុងការចិញ្ចឹម និងរកពូជយកមកដាក់ចិញ្ចឹម ។

### ២.១. ប្រភេទត្រីក្រៅស្រុក

#### ក. ត្រីកាបស (Silver carp )

- មានប្រភពមកពីប្រទេសចិន និងវៀតណាម
- រស់នៅ រកចំណីស៊ីនៅផ្ទៃលើ និងកណ្តាលនៃផ្ទៃទឹក
- ស៊ីចំណី កន្ទក់ ម្សៅពោត ជាពិសេសស៊ីប្លង់តុងរុក្ខជាតិ
- ការលូតលាស់លឿន ត្រីញីធំជាងត្រីឈ្មោល
- មិនធន់ និងងាយរងគ្រោះ ពេលទឹកស្រះរាក់ជាង ៧ តឹក



រូបភាព ២ : ត្រីកាបស ( Silver carp )

- មិនទំលាក់ពងក្នុងស្រះ ឬ ប្រឡាយ (បើគ្មានចរន្តទឹកហូរ) ជាប្រភេទត្រីពងលិចអណ្តែត
- ចិញ្ចឹម ១ ឆ្នាំ បានទំងន់ ពី ៧ ខាំ ទៅ ១ គីឡូក្រាម ក្នុង ១ ក្បាល ។

#### ខ. ត្រីកាបក្បាលធំ ( Bighead carp )

- មានប្រភពមកពីប្រទេសចិន
- រស់នៅ រកចំណីស៊ីផ្ទៃលើ និងកណ្តាលនៃផ្ទៃទឹក
- ស៊ីចំណី កន្ទក់ ម្សៅពោត ម្សៅសណ្តែកសៀង ជាពិសេសស៊ីប្លង់តុងសត្វ



រូបភាព ៣ ៖ ត្រីកាបក្បាលធំ ( Bighead carp)

- ការលូតលាស់លឿន ( ត្រីញីធំជាងត្រីឈ្មោល)
- មិនទំលាក់ពងក្នុងស្រះ ប្រឡាយ ( បើគ្មានចរន្តទឹកហូរ) ជាប្រភេទត្រីពងលិចអណ្តែត
- ចិញ្ចឹម ១ ឆ្នាំ បានទំងន់ ពី ៧ ខាំ ទៅ ១ គីឡូក្រាម ក្នុង ១ ក្បាល ។

### គ. ត្រីកាបសាមញ្ញ ( Common carp )

- មានប្រភពមកពីប្រទេសចិន
- រស់នៅ រកចំណីស៊ីស្រទាប់បាតនៃទឹកស្រះ
- ការលូតលាស់លឿន ជាពិសេសចិញ្ចឹមក្នុងស្រះចាស់
- ស៊ីចំណីនៅស្រទាប់បាត ដូចជា ជន្លេន ខ្យង សត្វល្អិតៗនៅបាតស្រះ ។ ក្រៅពីនេះ វាស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក ស្រូវបណ្តុះ ចកបាយទា ចកពងទឹក ។



រូបភាព ៤ ៖ ត្រីកាបសាមញ្ញ ( Common carp )

- ត្រីពងក្នុងស្រះ ឬ ប្រឡាយ ពេលមានភ្លៀងធ្លាក់ធំ ឬ បញ្ចូលទឹក
- ជាប្រភេទត្រីពងស្អិត (តោង) ជាប់នឹងរុក្ខជាតិក្នុងទឹក
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ៥ ខាំ ទៅ ១ គីឡូក្រាម ក្នុង ១ ក្បាល ។

### ឃ. ត្រីកាបឥណ្ឌា ( India carp )

- មានប្រភពមកពីប្រទេសឥណ្ឌា
- រស់នៅ និងរកចំណីស៊ីនៅស្រទាប់លើ និងបាតនៃទឹក
- ការលូតលាស់យឺតនៅឆ្នាំទី១ តែដល់ឆ្នាំទី ២ មានការលូតលាស់លឿន
- ស៊ីចំណីចំរុះ ដូចជា  កន្ទក់ ពោត ពន្លកគ្រាប់ធញ្ញជាតិ ចកបាយទា  ចកពងទឹក



រូបភាព ៥ : ត្រីកាបឥណ្ឌា ( India carp )

- រុក្ខជាតិរលួយនៅបាតស្រះ និងកាកសំណល់ផ្ទះបាយ
- ត្រីពងក្នុងស្រះ ឬ ប្រឡាយ (ធ្វើចរន្តទឹក ឬ បញ្ចូលទឹក)
- ជាប្រភេទត្រីពងលិចអណ្តែតក្នុងទឹក
- ធន់នឹងកន្លែងរស់នៅ  ធន់នឹងជំងឺ
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ៥ ខាំ ទៅ ៨ ខាំ  ក្នុង ១ ក្បាល ។

### ង. ត្រីទីឡាព្យា (Tilapia )

- មានប្រភពមកពីទ្វីបអាហ្វ្រិច
- រស់នៅ និងស៊ីចំណីនៅស្រទាប់លើ កណ្តាល និងបាតនៃផ្ទៃទឹក
- វាស៊ីចំណីចំរុះ ពពួកសត្វល្អិតៗ និងរុក្ខជាតិ ដូចជា ស្លែ សាលាដ៏ ផ្ចិ ចកពងទឹក ចកបាយទា ត្រកួន កន្ទំថេត កន្ទក់ ពោត ស្រូវបណ្តុះ និង កាកសំណល់ពីផ្ទះបាយ អាចម៍មាន់ អាចម៍ជ្រូក ។ល ។



រូបភាព ៦ : ត្រីទីឡាព្យា ( Tilapia )

- ត្រីពងកូនតាមបែបធម្មជាតិ ( ធ្វើសំបុកជាក្រឡុកនៅបាត និងជើងទេនៃស្រះ)
- ចិញ្ចឹម ១ ឆ្នាំ បានទំងន់ពី ៣ ខាំ ទៅ ៦ ខាំ ក្នុង ១ ក្បាល ។

## ច. ត្រីឃ្មើងក្របាច (Kissing gouramy )



រូបភាព ៧ : ត្រីឃ្មើងក្របាច (Kissing gouramy)

- មានប្រភពមកពីប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី...
- រស់នៅផ្ទៃលើ និងកណ្ដាលនៃផ្ទៃទឹក
- វាស៊ីចំណីចំរុះ ដូចជា កន្ទក់ ពោត បន្លែ ចក ត្រកួន សត្វល្អិត មមោត បាតស្រះ ស្លឹកកន្ធំថេត និង កាកសំណល់ពីផ្ទះបាយ អាចម៍មាន់ស្ងួត អាចម៍ជ្រូកស្ងួត ។ល ។
- ត្រីនេះមានប្រព័ន្ធដកដង្ហើមរង ធន់នឹងកន្លែងរស់នៅ ភាពចង្អៀត និងងាយដឹកជញ្ជូន
- ពងតាមធម្មជាតិនៅក្នុងស្រះ ឬ ប្រឡាយ  ពងបណ្ដែតនៅលើផ្ទៃទឹក
- ចិញ្ចឹម ១ ឆ្នាំ បានទំងន់ពី ២ ខាំ ទៅ ៣ ខាំ ក្នុង ១ ក្បាល ។

## ២.២. ប្រភេទត្រីក្នុងស្រុក

### ក. ត្រីឆ្ពិន (Silver barb )



រូបភាព ៨ : ត្រីឆ្ពិន (Silver barb )

- រស់នៅ រកចំណីស៊ីផ្ទៃលើ និងកណ្តាលនៃទឹកស្រះ
- ធន់នឹងកន្លែងរស់នៅ ជាពិសេសងាយចិញ្ចឹមក្នុងស្រះ ស្រែ ប្រឡាយ
- ស៊ីចំណីចំរុះ ដូចជា ស្លែ ត្រកួន ចកបាយទា ស្លឹកកន្ទំថេត ជន្ទល់ភ្នំ សារាយ កន្ទក់ ចុងអង្ករ ពោត សណ្តែក ស្រូវបណ្តុះ កណ្ឌៀរ កាកសំណល់ផ្ទះបាយ លាមកគោក្របី ជ្រូក មាន់ ។ល ។
- ត្រីញីធំជាងត្រីឈ្មោល ជាប្រភេទត្រីពងលិចអណ្តែត
- ពងក្នុងស្រះ ឬ ប្រឡាយ ( ពេលមានភ្លៀងធ្លាក់ធំ ឬ បញ្ចូលទឹកពេលព្រលប់)
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ៣ ខាំ ទៅ ៥ ខាំ ក្នុង ១ ក្បាល ។

### ខ. ត្រីកន្ធរ (Snakeskin gourami )

- រស់នៅ រកចំណីស៊ីនៅផ្ទៃលើ កណ្តាល និងបាតនៃទឹកស្រះ
- ស៊ីចំណីភាគច្រើនជាសារធាតុរលួយនៅបាតស្រះ ស្លែ ឬ រុក្ខជាតិរលួយក្នុងស្រះ
- ក្រៅពីនេះវាស៊ី កន្ទក់ ចុងអង្ករ ពោត និងកាកសំណល់ផ្ទះបាយ ឬ លាមកជ្រូកស្ងួត
- ចូលចិត្តរស់នៅកន្លែងណាទឹកមានសារធាតុរលួយ ( ស្មៅ ត្រកួន កំប្លោក ។ល ។)



រូបភាព ៩ : ត្រីកន្ធរ (Snakeskin gourami )

- ពងក្នុងស្រះ ឬ ប្រឡាយដែលមានរុក្ខជាតិដុះ ដោយពងរបស់វាអណ្តែតជាប់នឹងពពុះទឹក
- ធន់នឹងកន្លែងរស់នៅដែលមានសារធាតុរុក្ខជាតិរលួយ និងមិនសូវមានកើតជំងឺផ្សេងៗ
- ងាយចិញ្ចឹមក្នុងស្រះ ស្រែ ប្រឡាយ
- ពងក្នុងស្រះ ស្រែ ប្រឡាយ ( ធ្វើសំបុកជាពពុះទឹក មុននឹងពង)
- ជាប្រភេទត្រីពងអណ្តែតលើផ្ទៃទឹក
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ១ ខាំ ទៅ ២ ខាំ ក្នុង ១ ក្បាល ។

### គ. ត្រីព្រលូង (Mad barb )



រូបភាព ១០ : ត្រីព្រលូង (Mad barb )

- រស់នៅ រកចំណីស៊ីនៅផ្ទៃលើ កណ្តាល នៃទឹក
- ត្រីប្រភេទនេះ ស៊ីចំណីរុក្ខជាតិច្រើនជាង ដូចជា ផ្លែត្របែក ពុទ្រា ត្រសក់ ស្ពៃ សាលាដី ផ្ទី និងរុក្ខជាតិដុះក្នុងទឹក ដូចជា ត្រកួន ចកពងទឹក ចកបាយទា ។ល។
- ក្រៅពីនេះវាស៊ី កន្ទក់ ចុងអង្ករ ពោត ម្សៅដំឡូង ម្សៅសណ្តែកសៀង

- ត្រីញី និងត្រីឈ្មោលធំប្រហាក់ប្រហែលគ្នា
- ត្រីពងក្នុងស្រះ ឬ ប្រឡាយ ពេលធ្វើចរន្តទឹកក្នុងស្រះនៅពេលព្រលប់
- ជាប្រភេទត្រីពងលិចអណ្តែតក្នុងទឹក និងចិញ្ចឹមក្នុងបែមានការលូតលាស់ជាងចិញ្ចឹមក្នុងស្រះ
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ៤ ខាំ ទៅ ៦ ខាំ ក្នុង ១ ក្បាល ។

## ង. ត្រីប្រា ( Iridescent shark-catfish )



រូបភាព ១១ : ត្រីប្រា ( Iridescent shark-catfish )

- រស់នៅស្រទាប់ផ្ទៃកណ្តាល និងបាតនៃទឹកស្រះ
- ជាប្រភេទត្រីស៊ីចំណីចំរុះ កន្ទក់ ចុងអង្ករ ពោត សាច់ត្រី ចក និងកាកសំណល់ផ្ទះបាយ ។ល។
- ធន់នឹងកន្លែងរស់នៅ ធន់នឹងជំងឺ
- មិនទំលាក់ពងក្នុងស្រះ
- ចិញ្ចឹម ១ ឆ្នាំបានទំងន់ ពី ៨ ខាំ ទៅ ១,២ គីឡូក្រាមក្នុង ១ ក្បាល ។

## ច. ត្រីអណ្តែង ( Catfish )

- រស់នៅ និងរកចំណីស៊ីនៅស្រទាប់បាតនៃទឹកស្រះ
- ជាប្រភេទត្រីស៊ីចំណីចំរុះ ដូចជា កូនសត្វល្អិតៗ កំពឹស កូនត្រីតូចៗ ខ្យង លាមកសត្វ កន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ ។ល។
- ជំរៅទឹកដែលត្រីអណ្តែងរស់នៅសមស្របចាប់ពី ០,៥ ម៉ែត្រ ទៅ ១,៥ ម៉ែត្រ

- ធន់នឹងកន្លែងរស់នៅ ធន់នឹងជំងឺ
- អាចចិញ្ចឹមទោលក្នុងស្រះ លែងកូនត្រីពី ៥ ទៅ ៧ ក្បាល ក្នុង ១ ម៉ែត្រ
- ពងកូនក្នុងស្រះ បែបធម្មជាតិ តែបើត្រីអណ្ដែងបង្កាត់វិញមានពងតិចតួចណាស់
- ចិញ្ចឹម ៧ ខែ បានទំងន់ ពី ២ ខាំ ទៅ ៥ ខាំ ក្នុង ១ ក្បាល ។



រូបភាព ១២ : ត្រីអណ្ដែង ( Catfish )

## ៣. ការរៀបចំកន្លែងចិញ្ចឹមត្រី

### ៣.១. ជ្រើសរើសទីតាំងជីកស្រះ ឬ ប្រឡាយ

ការជីកប្រឡាយ ឬ ស្រះ គួរជ្រើសរើសទីកន្លែងអោយបានសមស្រប ដូចខាងក្រោម:

- នៅក្បែរផ្ទះ ងាយស្រួលការពារ និងថែរក្សា បានគ្រប់ពេល
- ដីមានកំរិតជ្រាបទឹកតិច ឬ បាតស្រះជាប្រភេទដីឥដ្ឋ ឬ ដីកណ្ដេង ( រក្សាទឹកបានយូរ)
- គ្មានសារធាតុពុលហូរចូលស្រះ ឬ ប្រឡាយ
- នៅទីវាលស្រលះ ( គ្មានដើមឈើធំៗ នៅជុំវិញស្រះ)
- មិនលិចទឹកនៅរដូវវស្សា
- នៅក្បែរប្រភពទឹកស្អាត
- ដីដែលមានគុណភាពសមស្របសំរាប់ជីកស្រះ
- នៅក្នុងតំបន់ដែលមានកន្លែងផលិតកូនត្រីពូជកាន់តែប្រសើរ ។



រូបភាព ១៣ ៈ ស្រះចិញ្ចឹមត្រីនៅទីកន្លែងស្រឡះ

## ៣.២. របៀបជីកស្រះ

មុនពេលជីកស្រះចិញ្ចឹមត្រីជំហានដំបូងត្រូវពិនិត្យគុណភាពដីសិន។ យើងអាចដឹងលក្ខណៈរបស់ដី ដោយជីកដីជំរៅ ១ ម៉ែត្រ រួចយកដីសើម មួយក្តាប់ពូតរួចបោះទៅលើ។ បើសិនដីនោះធ្លាក់មិនបែកជាកំទេចតូចៗ គឺដីនោះល្អ (ជីកស្រះដក់ទឹកបានយូរ)។ បើសិនដីធ្លាក់បែកជាកំទេចតូចៗ គឺដីជ្រាបទឹក ជីកស្រះចិញ្ចឹមត្រីមិនបានរយៈពេលយូរ ព្រោះឆាប៊ីរ៉ង (មិនដក់ទឹក)។ បើសិនជាកន្លែងជីកស្រះ ជាប្រភេទដីខ្សាច់ យើងយកដីឥដ្ឋមកទ្រាប់បាតស្រះកំរាស់ពី ១ តឹក ទៅ ១,៥ តឹក។



រូបភាព ១៤ ៈ ពិនិត្យគុណភាពដី ដើម្បីជីកស្រះ

ស្រះចិញ្ចឹមត្រី គប្បីជីករាងជាចតុកោណកែង (ទទឹងមិនគួរលើសពី ៣០ ម៉ែត្រ) ដើម្បីងាយអូសចាប់ត្រី។ ផ្ទៃក្រលាស្រះពី ១០០ ទៅ ៥០០ ម៉ែត្រការ៉េ ឬ ៣.០០០ ម៉ែត្រការ៉េ និងជំរៅស្រះពី ១,៥ ទៅ ២,៥ ម៉ែត្រ។ កំពស់ភ្លឺស្រះ ៦ តឹក ទៅ ៨ តឹក។ ជញ្ជាំងស្រះមានជើងទេរ (មិនចោតចុះពេក)។ បាតស្រះ ឬ ប្រឡាយរាបស្មើតែជំរាលមកកន្លែងបំពង់បង្ហូរទឹកចូលស្រះ ពីព្រោះ ងាយស្រួលក្នុងការស្តារ ឬ បូមប្រមូលផលត្រី។ លើកទំនប់ខ្ពស់មាំជុំវិញស្រះ ដើម្បីការពារទឹកភ្លៀងហូរកាត់។ រាំងស្បៃ ឬ ព្រួល មុនពេលបញ្ចូលទឹកក្នុងស្រះ ការពារត្រីកាចចូលស៊ីកូនត្រី។




រូបភាព ១៥ ៖ គំនូសកាត់ទទឹងស្រះ (មើលពីចំហៀងស្រះ)



រូបភាព ១៦ ៖ ជើងទេរនៃស្រះ និងជំរាលមួយចំហៀង

## ៣.៣. របៀបរៀបចំស្រះ ឬ ប្រឡាយថ្មី

**ជំហានទី ១ ៖** ជីកយកដីស្រែស្រទាប់លើធ្វើជាទំនប់ព័ទ្ធជុំវិញស្រះ ទុកចាក់ពីលើដីឥដ្ឋដែលជីកយកចេញពីស្រះនិងមួយចំនួនទៀតទុកទ្រាប់បាតស្រះ ។ អាចម៍ដីដែលជីកយកចេញពីស្រះត្រូវពង្រាយអោយទាបជាងភ្លឺស្រះ (ទំនប់ស្រះ) ការពារពេលភ្លៀងអាចម៍ដីហូរច្រោះចូលស្រះ ធ្វើអោយទឹកស្រះល្អក់ ។

**ជំហានទី ២ ៖** បញ្ចូលទឹកអោយលិចតែដីបាតស្រះ ឬ បាតប្រឡាយសិន ហើយត្រាំទុកពី ៣ ថ្ងៃ ទៅ ៤ ថ្ងៃ ដើម្បីបង្កើតអោយមានភក់ខ្លះៗ ដើម្បីអោយងាយកើតចំណីធម្មជាតិក្រោយពីដាក់ជីលាមកសត្វ និង រុក្ខជាតិ ។

**ជំហានទី ៣ ៖** បើសិនមានទឹកច្រើនពេក (ទឹកលិចភក់លើសពី ៣ តឹក) គឺយកទឹកចេញខ្លះ រួចបាច

កំបោរសភ្លាម (ដើម្បីអោយកំបោរមានប្រតិកម្មជាមួយភក់។ បរិមាណកំបោរសពី ១០ ទៅ ១៥ គីឡូក្រាមក្នុង ១០០ ម៉ែត្រការ៉េ នៃផ្ទៃស្រះ។

**ជំហានទី ៤ :** ហាលបាត (មិនអោយទឹកចូល) ស្រះ ឬ ប្រឡាយពី ៣ ទៅ ៥ ថ្ងៃ ដើម្បីកាត់បន្ថយជាតិជូរ ឬ ប្រៃនៅក្នុងស្រះ សំលាប់ពពួកមេរោគ និងធ្វើអោយទឹកថ្លា ដើម្បីងាយបង្កើតចំណីធម្មជាតិក្នុងស្រះ។

**ជំហានទី ៥ :** ដាក់ជីលាមកសត្វស្ងួត និងរុក្ខជាតិស្រស់ (ដូចជា ទន្ទ្រានខែត្រ សណ្តែកអង្រៃ កន្ទ្រាំងបាយសសារម៉ាវព្រៃ) ដាក់នៅក្នុងរណ្តៅតូចមួយ ដើម្បីអោយវារលួយសិន ទើបបង្ហូរចូលក្នុងស្រះ។

<u>ឧទាហរណ៍:</u> បើស្រះមានទំហំ ១០០ ម៉ែត្រការ៉េ។ គេដាក់ជីលាមកសត្វស្ងួត និងរុក្ខជាតិស្រស់ដូចខាងក្រោម:

- អាចម៍គោ ឬ អាចម៍ក្របីស្ងួត : ៨០ ទៅ ១០០ គីឡូក្រាម
- អាចម៍មាន់ស្ងួត : ១៥ ទៅ ២០ គីឡូក្រាម
- ទន្ទ្រានខែត្រស្រស់ : ៣០ ទៅ ៤០ គីឡូក្រាម ។





រូបភាព ១៧ : **ជីអាចម៍សត្វស្ងួត** ( គោ + មាន់) **និង រុក្ខជាតិស្រស់** (ទន្ទ្រានខែត្រ + សណ្តែកអង្រៃ)

**ជំហានទី៦ :** ក្រោយពីបន្ថែមទឹកចូលស្រះបានពី ៤ ទៅ ៥ ថ្ងៃ យើងសង្កេតឃើញទឹកមានពណ៌បៃតង ឬ ពណ៌ត្រួយចេក (ចំណីធម្មជាតិកើត) ពេលនោះទើបយើងលែងកូនត្រីចូលស្រះ។

### ៣.៤. របៀបរៀបចំស្រះ ឬ ប្រឡាយចាស់

ក. បើស្រះមានភក់រាក់ជាង ៥ តឹក មិនចាំបាច់ស្តារទេ។ យើងគ្រាន់តែប្រមូលសំរាមចេញ ជួសជុលជញ្ជាំង និងភ្លឺស្រះ។ បើមានមែកឈើគ្របច្រើនលើស្រះ ត្រូវកាត់ចេញខ្លះ ដើម្បីអោយមានពន្លឺថ្ងៃចាំងចូល។

ខ. បើស្រះមានភក់ជ្រៅលើស ៥ តឹក យើងស្តារភក់ចេញខ្លះ។ របៀបស្តារភក់បាតស្រះ ដូចខាងក្រោមៈ

**ជំហានទី១ :** យើងមិនត្រូវស្តារយកដីភក់ (ដីចាស់) ចេញពីបាតស្រះទាំងអស់នោះទេ គឺស្តារបានទំហំ ៣ ម៉ែត្រការ៉េ គឺយើងត្រូវទុកដីចាស់ខ្លះ (ដូចដំបូកកណ្តៀវ) ដើម្បីទុកពង្រាយពេលយើងស្តារបាតស្រះរួចរាល់ ។ ក្រោយពីពង្រាយដីនេះរួច អាចមានភក់ចាស់នេះនៅបាតស្រះមានកំរាស់ប្រហែលពី ២ ទៅ ៣ តឹក។

**ជំហានទី២ :** បញ្ចូលទឹកអោយលិចតែអាចម៍ដីបាតស្រះ ឬ ប្រឡាយសិន ហើយត្រាំទុកពី ៣ ថ្ងៃ ទៅ ៤ ថ្ងៃ ដើម្បីបង្កើតអោយមានភក់ខ្លះៗ ដើម្បីអោយងាយកើតចំណីធម្មជាតិក្រោយពីដាក់ជីលាមកសត្វ និង រុក្ខជាតិ។




**រូបភាព ១៨ : ទុកដីភក់ (ដីចាស់) នៅបាតស្រះ**

**ជំហានទី៣ :** បើសិនមានទឹកច្រើនពេក (ទឹកលិចភក់លើសពី ៣ តឹក) គឺត្រូវយកទឹកចេញខ្លះ រួចបាចកំបោរសភ្លាម (ដើម្បីអោយកំបោរមានប្រតិកម្មជាមួយភក់)ពី ៦ ទៅ ១០ គីឡូក្រាម ក្នុង ១០០ ម៉ែត្រការ៉េនៃផ្ទៃស្រះ (យកល្អបាចកំបោរពេលថ្ងៃក្តៅ ពីព្រោះ វាមានប្រតិកម្មជាមួយទឹក និងកំដៅបានល្អ)។ កុំបាចកំបោរសបាតស្រះណាដែលស្ងួត (គ្មានភក់) ពីព្រោះ វាគ្មានប្រតិកម្មជាមួយដីទេ។

**ជំហានទី៤ :** ហាលបាតស្រះ ឬ ប្រឡាយចោលពី ៣ ទៅ ៥ ថ្ងៃ ដើម្បីកាត់បន្ថយដូចជាជាតិជូរ ឬប្រៃនៅក្នុងស្រះ សំលាប់ពពួកមេរោគ និងធ្វើអោយទឹកងាយថ្លា ដើម្បីងាយស្រួលបង្កើតចំណីធម្មជាតិក្នុងស្រះ។

**ជំហានទី៥ :** គេដាក់ជីលាមកសត្វស្ងួត និងរុក្ខជាតិស្រស់ ( ដូចជា ទន្រ្ទានខែត្រ សណ្តែកអង្រៃ កន្រ្ទាំងបាយស សាវម៉ាវព្រៃ) ដាក់នៅក្នុងរណ្តៅតូចមួយ ដើម្បីអោយវារលួយសិន ទើបបង្ហូរចូលក្នុងស្រះ។

**ជំហានទី៦ :** បញ្ចូលទឹកចូលក្នុងស្រះមានកំពស់ទឹក ៥ តឹក ហើយត្រាំទុកពី ៣ ទៅ ៥ ថ្ងៃ ឬ ១ អាទិត្យ ដើម្បីអោយមេចំណីធម្មជាតិកើត (ប្លង់តុង)។ បន្ទាប់មកបន្ថែមទឹកចូលស្រះ ឬ ប្រឡាយ អោយពេញស្រះ។ ក្រោយពីបន្ថែមទឹកចូលស្រះបានពី ៤ ទៅ ៥ ថ្ងៃ យើងសង្កេតឃើញទឹកមានពណ៌ត្រួយចេក (ចំណីធម្មជាតិកើត) ពេលនោះ ទើបយើងចាប់ផ្តើមលែងកូនត្រីចូលស្រះ។



រូបភាព ១៩ : បាចកំបោរស រួចលាលផ្ទៃបាតស្រះ

**ផលប្រយោជន៍នៃការរាចកំបោរសៈ** ការបាចកំបោរសមានសារៈប្រយោជន៍ ដូចជា សំលាប់មេរោគមួយចំនួននៅក្នុងស្រះ ជួយរក្សាកំរិតជាតិជូរ និងប្រៃនៃទឹកស្រះ ធ្វើអោយទឹកឆាប់ថ្លា ។ ចំណីធម្មជាតិងាយកើត ក្រោយពីបានដាក់អាចម៍គោ ឬ អាចម៍ក្របីស្ងួត ដាក់ទន្រ្ទានខែត្រស្រស់ និងបញ្ចូលទឹកបានពី ៤ ទៅ ៧ថ្ងៃ។

<u>ឧទាហរណ៍:</u> បើស្រះមានទំហំ ១០០ ម៉ែត្រការ៉េ ។ គេដាក់ជីលាមកសត្វស្ងួត និងរុក្ខជាតិស្រស់ដូចខាងក្រោមៈ

- អាចម៍គោ ឬ អាចម៍ក្របីស្ងួត : ៥០ ទៅ ៧០ គីឡូក្រាម
- អាចម៍មាន់ ឬ អាចម៍ជ្រូកស្ងួត : ១៥ ទៅ ២០ គីឡូក្រាម
- ទន្រ្ទានខែត្រស្រស់ : ២០ ទៅ ៣០ គីឡូក្រាម



រូបភាព ២០ : យើងលែងកូនត្រី នៅពេលឃើញទឹកស្រះមានពណ៌បណ្តូលចេក

## ៤. គុណភាពទឹក

គុណភាពទឹកជាកត្តាសំខាន់បំផុតក្នុងការជ្រើសរើសកន្លែងជីកស្រះ និងផ្គត់ផ្គង់ទឹកក្នុងការចិញ្ចឹមត្រី ។

### ៤.១ របៀបត្រួតពិនិត្យគុណភាពទឹក

មុននឹងលែងកូនត្រី គេត្រួតពិនិត្យគុណភាពទឹកស្រះជាមុនសិន តាមវិធី ដូចខាងក្រោម:

#### ក. ពិនិត្យតាមសកម្មភាពមនុស្ស

☞ ជ្រលក់ចង្អុលដៃ



យកចង្អុលដៃជ្រលក់ក្នុងទឹកស្រះដែលបំរុងដាក់ត្រីចិញ្ចឹម រួចលិទ្ធ ។ បើសិនជាទឹកមានជាតិជូរគឺ ទឹកនោះ មិនលែងកូនត្រីបានទេ ពីព្រោះ ពិបាកបង្កើតចំណីធម្មជាតិ ត្រីលូតលាស់យឺត និងត្រីងាយកើតជំងឺ ។

☞ ប្រើទឹកម្លូរហូប



យកទឹកម្លូរហូបបន្តក់ចូលទឹកស្រះ បើសិនទឹកស្រះមានពណ៌ក្រហមដូចទឹកម្លូរដដែលគឺ ទឹកល្អ ។ បើសិនទឹកមានពណ៌ខ្មៅគឺ មិនលែងកូនត្រីបានទេ ពីព្រោះទឹកជូរពិបាកបង្កើតចំណីធម្មជាតិ ត្រីលូតលាស់យឺត និង ត្រីងាយកើតជំងឺ ។

☞ ប្រើសាប៊ូបោកខោអាវ




ដួសទឹកស្រះចាក់ចូលក្នុងកាធុន ចាក់សាប៊ូចូលយកដៃកូរ ។ បើសិនទឹកមានពពុះច្រើន ហើយឆាប់អស់ពពុះ គឺ មិនលែងកូនត្រីបានទេ ។ តែបើសិនទឹកនោះ មានពពុះតិច មានន័យថា ទឹកមាន ជាតិជូរ វាពិបាកក្នុងការ បង្កើតចំណីធម្មជាតិ និង ធ្វើអោយត្រីលូតលាស់យឺត និង ត្រីងាយកើតជំងឺ ។

បភាព ២១ : របៀបពិនិត្យគុណភាពទឹកស្រះ

### ខ. ពិនិត្យតាមសកម្មភាពរបស់ត្រី

មុនដាក់កូនត្រីចិញ្ចឹម គេចងស្បៃដាក់ក្នុងស្រះដែលបំរុងចិញ្ចឹមត្រី រួចយកកូនត្រីចំនួន ៣០ ទៅ ៥០ ក្បាល ដាក់ក្នុងស្បៃនោះ ដើម្បីសាកល្បងមើលក្នុងរយៈពេល ៣ ទៅ ៥ ថ្ងៃ។ បើសិនឃើញកូនត្រីក្នុងស្បៃនោះងាប់ជាបន្តបន្ទាប់មានន័យថា ទឹកស្រះមិនទាន់ដាក់ត្រីចិញ្ចឹមបានទេ តែបើសិនមិនឃើញកូនត្រីនោះងាប់ទេ អាចចិញ្ចឹមបាន។

### ៤.២ របៀបពិនិត្យ និងវាយតំលៃពណ៌ទឹកស្រះចិញ្ចឹមត្រី

- ទឹកពណ៌បៃតង: មានន័យថា ប្លង់តុងរុក្ខជាតិ និងប្លង់តុងសត្វកើតគ្រប់គ្រាន់ជាចំណីត្រី។
- ទឹកពណ៌បៃតងចាស់: មានន័យថា ប្លងតុងកើតខ្លាំង។ ដូចនេះ ត្រូវផ្អាកការដាក់ជី ឬ ត្រូវបន្ថែមទឹកថ្មីចូល ឬ ប្តូរទឹកចាស់ចេញពី ៣០ ទៅ ៥០ ភាគរយ នៃបរិមាណទឹកក្នុងស្រះ។
- ទឹកល្អក់: ស្រះទើបជីករួច ឬ ដីថ្មីហូរចូលពេលភ្លៀង ឬ មិនបានបាចកំបោរស។ បើស្រះបានដាក់ត្រីចិញ្ចឹមគឺ លែងពពួកត្រីស៊ីចំណីស្រទាប់បាតច្រើនពេក ( ត្រីកាបសាមញ្ញ ឬ ត្រីកាបឥណ្ឌា)
- ទឹកថ្លា: មានន័យថា ខ្សត់ចំណីធម្មជាតិ គេដាក់អាចម៍សត្វស្ងួត និងទន្រ្ទានខៃត្រស្រស់បន្ថែម។
- ទឹកពណ៌ទឹកតែ: មានន័យថា ស្រះមានស្លឹកឈើជ្រុះចូលច្រើន ឬ ស្រះទទួលបានពន្លឺថ្ងៃមិនគ្រប់គ្រាន់ ឬ មានរុក្ខជាតិដុះក្នុងស្រះងាប់រលួយ ធ្វើអោយត្រីមានការលូតលាស់យឺត និងត្រីងាយពុល។
- កំរិតថ្លានៃទឹក: ពន្លឺចាំងចូលក្នុងទឹកមានកំរិតថ្លានៃទឹកស្រះពី ៣ ទៅ ៤ តឹក។

## ៥. របៀបរៀបចាប់ វេចខ្ចប់ ដឹកជញ្ជូន និងលែងកូនត្រី

នៅដើមរដូវវស្សា តាមតំបន់មួយចំនួនមានទឹកនៅតាមវាលស្រែ និងស្រះបង្កលក្ខណៈអំណោយផលដល់ការចិញ្ចឹមត្រីនៅតំបន់នោះ។ ប៉ុន្តែទន្ទឹមនឹងនេះ វាក៏ជាផលវិបាកមួយដែរ ប្រសិនដាក់ត្រីចិញ្ចឹមមានការយឺតយ៉ាវនោះនឹងធ្វើអោយអត្រាបាត់បង់កូនត្រីខ្ពស់ (ត្រីស្រែចូលមកនៅមុន)។ ដូចនេះ ដើម្បីកាត់បន្ថយការបាត់បង់កូនត្រី គប្បីលែងកូនត្រីនៅដើមរដូវវស្សា ពីព្រោះ ពពួកសត្វបំផ្លាញកូនត្រីមិនទាន់កើតច្រើន ដូចជា ពពួកត្រីកាចអន្ទង់ ក្តាម កង្កែប កន្លង់ កន្ទៀទូក ។ល។

### ៥.១ របៀបបង្វឹកកូនត្រី

ដើម្បីកាត់បន្ថយអត្រាងាប់របស់កូនត្រីពេលដឹកជញ្ជូន និងលែងចូលស្រះ យើងគប្បីធ្វើតាមជំហាន ដូចខាងក្រោម:

● **ជំហានទី ១ :** មុនពេលក្បៀរចាប់កូនត្រី ដំបូងគេត្រូវបង្អឹកកូនត្រីរយៈពេលពី ២ ទៅ ៣ថ្ងៃ ជាមុនសិន ដោយគេមិនដាក់ចំណីអោយស៊ីក្នុងរយៈពេលបង្អឹកនេះ។ ការបង្អឹកកូនត្រី ១ ដង ក្នុង ១ ថ្ងៃ នៅល្ងាចទឹកត្រជាក់ ដោយប្រើអួន អញ្ចង ដើម្បីអោយកូនត្រីធន់នឹងកន្លែងរស់នៅមានទឹកល្អ ហើយនៅពេលដាក់ចូលក្នុងហាប៉ាមានអត្រារស់ ខ្ពស់។ ក្បៀរកូនត្រីមកជ្រុងម្ខាងនៃស្រះទុកប្រហែល ១០ ទៅ ១៥ នាទី ក្រោយមកពន្លិចសាច់ហាប៉ា ឬ អួនអោយកូនត្រីហែលចេញទៅវិញ។



**រូបភាព ២២ : ពន្លិចអួនអោយកូនត្រីហែលចេញពីក្នុងអួន**

● **ជំហានទី ២ :**

ក្បៀរកូនត្រីមកដាក់ក្នុងហាប៉ាស្រះមានទឹកស្អាត និងមិនដាក់ចំណីអោយស៊ីទេ។ មុនពេលដឹកកូនត្រីទៅកន្លែង ចិញ្ចឹម គឺស្តុកកូនត្រីក្នុងហាប៉ារយៈពេលតិចបំផុត ២៤ ម៉ោង ដើម្បីអោយកូនត្រីទំលាក់អាចម៍ និងអោយធន់ភាព ចង្អៀតជាមុនសិន ជៀសវាងនៅពេល ដឹកកូនត្រីបញ្ចេញអាចម៍ច្រើនក្នុងថង់ វាធ្វើអោយកូនត្រីពុល និងងាប់ច្រើន។




**រូបភាព ២៣ : បន្សាំកូនត្រីក្នុងហាប៉ាមុនពេលដឹកជញ្ជូន (រយៈពេលតិចបំផុត ២៤ ម៉ោង)**

### ៥.២ របៀបវេចខ្ចប់កូនត្រីដោយបិទជិត (ថង់ប្លាស្ទិក)

ពេលចាប់កូនត្រីរាប់កូនត្រី យើងត្រូវត្រៀមសំភារៈ ដូចជា កាធុនជ័រ ចានចង្អឹះ ថង់កៅស៊ូ ទឹកស្អាត ធុងខ្យល់អុកស៊ីសែន និងកៅស៊ូកងសំរាប់រុំចង។ ទំហំថង់: ៦ តឹក X ១០ តឹក។ ប្រើថង់ ២ ជាន់ការពារធ្លាយ។



រូបភាព ២៤ : របៀបរាប់កូនត្រីដាក់ក្នុងថង់

ជំហានទី ១ : ត្រូវពិនិត្យថង់កៅស៊ូមានធ្លុះធ្លាយឬអត់។ បើដឹកផ្លូវឆ្ងាយត្រូវដាក់ថង់កៅស៊ូ២ជាន់ និងដាក់សំបកបាវស៊ីម៉ង់ត៍ពីខាងក្រៅថង់ការពារការប៉ះ ឬ ធ្លាយ ធ្វើអោយអស់ខ្យល់ពីថង់ (កូនត្រី ងាប់)។ ចងក្បួចគូទថង់ ដោយប្រើកៅស៊ូកង។





រូបភាព ២៥ : ដាក់សំបកបាវស៊ីម៉ង់ត៍ពីខាងក្រៅ និងថង់ដាក់កូនត្រីខាងក្នុង

**ជំហានទី២ :** បញ្ចូលទឹកស្អាតចូលក្នុងថង់កៅស៊ូប្រមាណ ១ ភាគ ៣ នៃមាឌថង់។ រួចរាប់កូនត្រីដាក់ចូលក្នុងថង់បន្ទាប់មកបញ្ចូលខ្យល់អុកស៊ីហ្សែន។ ចំនួនកូនត្រីស្តុកក្នុងថង់អាស្រ័យ នឹងទំហំកូនត្រី ឬ ប្រវែងកូនត្រី (កូនត្រីតូច ឬ ធំ)។

➢ ការដឹកជញ្ជូនផ្លូវឆ្ងាយ :

បញ្ចូលខ្យល់អុកស៊ីហ្សែនក្នុងថង់កូនត្រីអោយណែន រួចប្រើកៅស៊ូកង ដើម្បីចងរិត។



រូបភាព ២៦ : បញ្ចូលខ្យល់អុកស៊ីហ្សែនក្នុងថង់ដាក់កូនត្រី

➢ ការដឹកជញ្ជូនផ្លូវជិត : *(ប្រើខ្យល់ធម្មជាតិ ឬ ខ្យល់បរិយាកាស)*

ចំហមាត់ថង់អោយចំទិសខ្យល់ ឬ គ្រវីមាត់ថង់អោយខ្យល់ចូលថង់ រួចក្របួចមាត់ថង់អោយជាប់ បន្ទាប់មកស៊កបញ្ចូលទៅនឹងថង់ដាក់កូនត្រី រួចប្រើកៅស៊ូកង ដើម្បីចងរិត។ បើប្រើខ្យល់ធម្មជាតិដឹកមិនបានយូរទេរ គឺបញ្ចូលភ្លាម ដឹកចេញទៅភ្លាម (រយៈពេលដឹកពី ៣០ ទៅ ៤០ នាទី ប៉ុណ្ណោះ)។

ពេលដឹកកូនត្រីទៅកន្លែងឆ្ងាយគឺកុំដាក់ថង់កូនត្រីត្រូវកំដៅថ្ងៃ ឬ ដាក់ហាលថ្ងៃ វាធ្វើអោយបាត់បង់អុកស៊ីហ្សែន ឬ ខ្យល់ក្នុងថង់ ហើយវាអាចបំលែងទៅជាតិពុលក្នុងថង់ (កូនត្រីងាប់)។ ដូច្នេះ នៅពេលដឹកកូនត្រីគប្បីដាក់កំប្លោក ឬ ក្រាលក្រណាត់ជ្រលក់ទឹកគ្របពីលើថង់កូនត្រី។ ពេលដឹកកូនត្រីមិនអោយលើស ៣ ទៅ ៤ ម៉ោង បើសិនលើសពីម៉ោង នេះ ឬ ថង់ដាក់កូនត្រីធូរខ្យល់ (អស់ខ្យល់) ត្រូវប្តូរទឹក និងបញ្ចូលខ្យល់សារជាថ្មី។

ការស្តុកកូនត្រីក្នុងថង់ គឺ អាស្រ័យទៅតាមទំហំកូនត្រីដែលត្រូវដឹកជញ្ជូន ដូចជា :

- កូនត្រីស្តុកពី ៥០០ ទៅ ៦០០ ក្បាល ក្នុង ១ ថង់ ប្រវែងកូនត្រីពី ២ ទៅ ៣ ហ៊ុន
- កូនត្រីស្តុកពី ៣០០ ទៅ ៤០០ ក្បាល ក្នុង ១ ថង់ ប្រវែងកូនត្រីពី ៣ ទៅ ៤ ហ៊ុន
- កូនត្រីស្តុកពី ២០០ ទៅ ៣០០ ក្បាល ក្នុង ១ ថង់ ប្រវែងកូនត្រីពី ៤ ទៅ ៦ ហ៊ុន

## ៥.៣. ដឹកជញ្ជូនកូនត្រីដោយចំហ (ធុងជ័រ ប៉ោត កានជ័រ...)

ដឹកកូនត្រីដោយចំហទៅកន្លែងជិតៗ ដូចជា ពីកន្លែងបន្សាំកូនត្រី ឬ កន្លែងស្ថានីយ៍ផលិតពូជត្រី ទៅកន្លែងចិញ្ចឹមត្រី។ គប្បីដាក់សារាយស្រស់ក្នុងប៉ោតកានជ័រ (ចំណុះទឹក ១០ លីត្រ ថែមសារាយស្អាត ០,៣ ទៅ ០,៥ គ.ក្រ) ដើម្បីកាត់បន្ថយរបួសស្នាម ដោយសារការបោក ឬ ទង្គិចគ្នា ឬ គ្រលុកទឹកក្នុងឧបករណ៍ដាក់ត្រីនោះ។

- ចំនួនកូនត្រី ៤០ ក្បាល ក្នុង ១ លីត្រទឹក ចំពោះកូនត្រីប្រវែងដងខ្លួន ៣ ហ៊ុន
- ចំនួនកូនត្រី ២០ ក្បាល ក្នុង ១ លីត្រទឹក ចំពោះកូនត្រីប្រវែងដងខ្លួន ៦ ហ៊ុន ។



រូបភាព ២៧: ដាក់កូនត្រីក្នុងកានជ័រ ឬ ប៉ោត

## ៥.៤. របៀបលែងកូនត្រី

ដឹកកូនត្រីនៅពេលមេឃត្រជាក់ (ព្រឹក ឬ ល្ងាច) ពីព្រោះ កំដៅព្រះអាទិត្យទាប មិនធ្វើអោយប៉ះពាល់សុខភាពកូនត្រីពេលដឹកជញ្ជូន។ មុននឹងលែងកូនត្រីចូលក្នុងស្រះត្រូវដាក់ត្រាំថង់កូន ត្រីក្នុងទឹកស្រះ ឬ ប្រឡាយពី ១៥ ទៅ ២០ នាទី ដើម្បីអោយកំដៅទឹកក្នុងថង់កូនត្រី និង ទឹកស្រះមានភាពប្រហាក់ប្រហែលគ្នាផង និងការកាត់បន្ថយការនឿយហត់របស់ត្រីផង។



រូបភាព ២៨ : ត្រាំថង់កូនត្រី និងបំប៉នក្នុងឃោចាំ

បើសិនកូនត្រីមានប្រវែងដងខ្លួនពី ៣ ទៅ ៤ ហ៊ុន គេត្រូវបំប៉នកូនត្រីក្នុងហាប៉ាអោយធំជាងបន្តិច ទើបលែងចូលស្រះ ឬ ប្រឡាយ ។

យកដៃកូរទឹកពីមុខមាត់ថង់ និងបាចទឹកតិច១ខាងក្រៅចូលក្នុងថង់កូនត្រី ហើយអោយកូនត្រីហែលចេញតាមសំរួល ។ គប្បីលែងកូនត្រីនៅម៉ោង ៩ ព្រឹក ឬ ម៉ោង ៦ ល្ងាច ទើបកូនត្រីមានសុខភាពល្អ និងមិនងាប់ ពីព្រោះពេលនេះទឹកមិនសូវក្តៅ ។



**រូបភាព ២៩ : លែងកូនត្រីចូលក្នុងស្រះ**

កុំលែងកូនត្រីពេលមេឃកំពុងភ្លៀង ពីព្រោះ ទឹកភ្លៀងមានជាតិអាស៊ីតជាតិជូរនៅស្រទាប់លើនៃផ្ទៃទឹកធ្វើអោយកូនត្រីងាប់ ។ អាចលែងកូនត្រីបានក្រោយពីភ្លៀងរាំង ១ ម៉ោង ពីព្រោះ ទឹកស្រះបានលាយជាមួយទឹកភ្លៀងបន្ថយជាតិអាស៊ីត ។

### ៥.៥. ប្រភេទត្រី ប្រវែងដងខ្លួនកូនត្រី និង ចំនួនកូនត្រីដាក់ចិញ្ចឹម

ដើម្បីចិញ្ចឹមត្រីទទួលបានផលល្អ និងមានអត្រាបាត់បង់តិច យើងគួរគិតដល់ទំហំកូនត្រី និងចំនួនកូនត្រីដែលត្រូវដាក់ចិញ្ចឹមក្នុងស្រះអោយសមស្របតាមបច្ចេកទេស ។ បើសិនជាយើងលែងកូនត្រីចូលក្នុងស្រះច្រើនពេក ហើយការផ្តល់ចំណី និងគ្រប់គ្រងទឹកមិនបានល្អ វាអាចធ្វើអោយត្រីចិញ្ចឹមរបស់យើងមានការលូតលាស់យឺត ( មិនធំ) និង អាចធ្វើអោយត្រីបាត់បង់ច្រើន (ងាប់) ។ ក្រៅពីនេះ យើងក៏គួរជ្រើសរើសកូនត្រីមានសុខភាពល្អហែលរហ័សរហួន រូបរាងមាំមួន ពណ៌ស្រស់ គ្មានរបួស ឬ ដំបៅ និងគ្មានជំងឺ ។ ដូច្នេះ ដើម្បីចិញ្ចឹមបានល្អគួរលែងកូនត្រី ៣ ក្បាល ក្នុង ១ ម៉ែត្រការ៉េ នៃផ្ទៃស្រះ ។ កូនត្រីដែលលែងគួរតែមានប្រវែងដងខ្លួនពី ៤ ទៅ ៦ ហ៊ុន ។

**ឧទាហរណ៍:** បើសិនអ្នកមានស្រះទំហំ ១០០ ម៉ែត្រការ៉េ ។ អ្នកគួរលែងកូនត្រីចំនួន ៣ ក្បាល ក្នុង ១ ម៉ែត្រការ៉េ នៃផ្ទៃស្រះ ។ ដូច្នេះ ចំនួនកូនត្រីសរុបដែលត្រូវលែងចូលក្នុងស្រះមាន:

ស្រះទំហំ ១០០ ម៉ែត្រការ៉េ ស្មើនឹង = ១០០ × ៣ = ៣០០ ក្បាល

*ចិញ្ចឹមប្រភេទត្រី:* បើលែងកូនត្រីច្រើនប្រភេទទៅក្នុងស្រះតែមួយ ហើយក្នុងនោះមានប្រភេទត្រី គេលែងត្រីកាបសាមញ្ញ និងត្រីកាបឥណ្ឌា មិនអោយលើស ១០ ភាគរយ ធៀបនឹងចំនួនកូនត្រីសរុបដែលលែងក្នុងស្រះ ពីព្រោះ កាលណាលែងកូនត្រីកាបសាមញ្ញ ឬ កាបឥណ្ឌាច្រើន វាធ្វើអោយទឹកស្រះល្អក់ ហើយអាចធ្វើ អោយប៉ះពាល់ដល់ការដកង្ហើម និងការចាប់ចំណីនៃប្រភេទត្រីផ្សេងទៀត ជាពិសេសការបង្កើតចំណីធម្មជាតិក្នុងស្រះ ដោយសារប្រភេទត្រីកាបសាមញ្ញ និងកាបឥណ្ឌានេះវារកចំណីស៊ីនៅបាតស្រះ (ត្បុលដីភក់) ដើម្បីចាប់ចំណីស៊ី។






**រូបភាព ៣០ : ប្រវែងខ្លួនកូនត្រីលែងចូលក្នុងស្រះ**

## ៦. ប្រភេទចំណីត្រី

ចំណីត្រី ដូចជា សារាយ ត្រកួន ចកពងទឹក ចកបាយទា ស្លែ សាលាដ់ ស្លឹកអង្គាដី ស្លឹកផ្លែកន្ធំថេត ពោតផ្លែពុទ្រា ជន្ទល់ភ្នំ ដំឡូង កន្ទក់ ចុងអង្ករ កណ្ដៀវ អង្រ្កង ដង្កូវ ជន្លេន កាកសំណល់ផ្ទះបាយ ដីកំប៉ុស្ត ។ល។




**រូបភាព ៣១ : ប្រភេទចំណីធម្មជាតិ**

### ក. ការផ្សំចំណី

ប្រភេទចំណីនីមួយៗមានសារៈសំខាន់ក្នុងការលូតលាស់របស់ត្រី។ ដើម្បីអោយត្រីមានការលូតលាស់ល្អគួរផ្សំចំណី ដូចជា កន្ទក់ ៥០ ភាគរយ ចុងអង្ករ ១៤ ភាគរយ សណ្ដែកសៀង ១៤ ភាគរយ បន្លែ ២០ ភាគរយ

និងអំបិល ២ ភាគរយ ។ ចំពោះចំណីបន្ថែម ដូចជា សារាយ ត្រកួន ចកពងទឹក ចកបាយទា អង្កាដី កន្ធំថេត ពោត ដំឡូង កណ្ដៀរ អង្រ្កង ដង្កូវ ជន្លេន កាកសំណល់ផ្ទះបាយ ។ល ។




រូបភាព ៣២ : ស្ងោរចំណីអោយត្រីស៊ី

ឧទាហរណ៍: ចំណីសរុប ១ គីឡូក្រាម មានធាតុផ្សំចំណី ដូចខាងក្រោម:

- កន្ទក់ ៥០ ភាគរយ ស្មើនឹង ០,៥ គីឡូក្រាម នៃចំណីសរុប
- ចុងអង្ករ ១៤ ភាគរយ ស្មើនឹង ០,១៤ គីឡូក្រាម នៃចំណីសរុប
- សណ្ដែកសៀង ឬ ម្សៅត្រី ១៤ ភាគរយ ស្មើនឹង ០,១៤ គីឡូក្រាម នៃចំណីសរុប
- បន្លែ ២០ ភាគរយ ស្មើនឹង ០,២០ គីឡូក្រាម នៃចំណីសរុប
- អំបិល ២ ភាគរយ ស្មើនឹង ០,០២ គីឡូក្រាម នៃចំណីសរុប ។

ចំណីដែលត្រូវផ្ដល់អោយត្រី យកល្អគួរចំអិនជាមុនសិន ពីព្រោះ ត្រីចូលចិត្តស៊ី ហើយអាចឆាប់ធំ ។ បរិមាណចំណីអោយស៊ីស្មើនឹង ៣ ភាគរយ (អោយត្រីធំ) និងពី ៤ ទៅ ៥ ភាគរយ (អោយត្រីនៅតូច) នៃទំងន់ខ្លួនត្រីសរុបនៅក្នុងស្រះ ។ បរិមាណចំណីត្រូវបង្កើនតាមទំងន់ត្រីជាលំដាប់ ។

**តារាង ១ បរិមាណចំណីផ្ដល់អោយត្រីស៊ីក្នុង ១ ថ្ងៃ (គិតជាភាគរយ) នៃទំងន់ខ្លួនត្រីសរុបក្នុងស្រះ**

| ទំងន់ត្រី | បរិមាណចំណីអោយស៊ី (ភាគរយ) នៃទំងន់ខ្លួនត្រីសរុបក្នុងស្រះ |
|---|---|
| ៥០ ទៅ ១០០ ក្រាម ក្នុង ១ ក្បាល | ៤ ទៅ ៥ ភាគរយ |
| ១០០ ទៅ ៣០០ ក្រាម ក្នុង ១ ក្បាល | ៣ ទៅ ៤ ភាគរយ |
| ចាប់ពី ៣០០ក្រាម ក្នុង ១ក្បាល ឡើងទៅ | ៣ ភាគរយ |

តារាង ២ របៀបគណនាបរិមាណចំណីផ្តល់អោយត្រីស៊ីក្នុង ១ ថ្ងៃ

| ចំនួនត្រី ( ក្បាល) | ទំងន់ត្រី (ក្រាម/ក្បាល) | បរិមាណអោយស៊ីក្នុង ១ ថ្ងៃ ( ៣ ទៅ ៥ ភាគរយ នៃទំងន់ខ្លួនត្រីសរុប ) |
|---|---|---|
| ៣០០ | ៥០ ក្រាម/៣០០ ក្បាល | ៥០ ក្រាម × (៥/១០០) = ៧៥០ ក្រាម ឬ ០,៧៥ គ.ក្រ |
| ៣០០ | ៣០០ ក្រាម/ ៣០០ ក្បាល | ០,៣ គ.ក្រ × (៣/១០០) = ២,៧ គ.ក្រ |

**កំណត់សំគាល់:**

*១ ខាំ = ១០០ ក្រាម　　១០០០ ក្រាម = ១ គីឡូក្រាម　(១ គីឡូក្រាម = ១០ ខាំ)*



រូបភាព ៣៣ : ពិនិត្យចំណី និងបរិមាណត្រីនៅក្នុងកន្ត្រងដាក់ចំណី

## ខ. ទីកន្លែងអោយចំណី

- កន្លែងដាក់ចំណី: គេធ្វើស៊ុមបណ្តែតសំរាប់ដាក់ប្រភេទចំណីណាដែលអណ្តែត ដូចជា ចកបាយទាស្លែ ត្រកួន សាលាដ់.....។ តែចំពោះចំណីណាដែលលិចក្នុងទឹក គេធ្វើស៊ុមជាថ្នេរដាក់ខ្សែទាញចុះឡើង ហើយចំណីត្រូវបានដាក់ពន្លិចចូលក្នុងទឹក។



រូបភាព ៣៤ : ស៊ុចដាក់ចំណីត្រី

◆ ពេលវេលានៃការផ្តល់ចំណី :

យើងអោយចំណីត្រីស៊ីចំនួន ២ ដង ក្នុង ១ ថ្ងៃ គឺ នៅចន្លោះ ម៉ោង ៨ ទៅ ៩ ព្រឹក និង នៅចន្លោះ ម៉ោង ៥ ទៅ ៦ ល្ងាច ( ត្រីស៊ីចំណីពេលល្ងាចច្រើនជាងពេលព្រឹក) ពីព្រោះ ទឹកត្រជាក់មិនធ្វើអោយប៉ះពាល់ដល់ការរំលាយអាហារ និង ដកដង្ហើមរបស់ត្រី ។



រូបភាព ៣៥ : ត្រួតពិនិត្យការស្រូតលាស់របស់ត្រីពេលដាក់ចំណី

### គ. ស្រះចិញ្ចឹមត្រីភ្ជាប់ទៅនឹងស្រែ

ដើម្បីអោយត្រីចិញ្ចឹមក្នុងស្រះមានការលូតលាស់រហ័ស និងកាត់បន្ថយការចំណាយចំណីផ្តល់អោយស៊ីប្រចាំថ្ងៃ។ គេជីកជាប្រព័ន្ធប្រឡាយ ឬ ជ្រលងទឹកក្នុងស្រែធ្វើជាផ្លូវអោយត្រីចេញចូលពីស្រះទៅស្រែ ដើម្បីអោយប្រើស្វែងរកចំណីធម្មជាតិនៅក្នុងស្រែ។ ប៉ុន្តែ គេត្រូវចិញ្ចឹមត្រីក្នុងស្រះមួយរយៈសិន ដើម្បីអោយកូនត្រីមានប្រវែងដងខ្លួនពី ៨ ទៅ ១២ ហ៊ុន ទើបលែងចូលក្នុងស្រែ ពីព្រោះ នៅក្នុងស្រែសំបូរដោយពពួកសត្រូវ ដូចជា ត្រីកាច ពស់ អន្ទង់ កង្កែប ក្តាម កណ្តុរ។



រូបភាព ៣៦ : ការផ្តល់ចំណីបន្ថែម និង ចិញ្ចឹមត្រីក្នុងស្រះភ្ជាប់ទៅនឹងស្រែ

## ៧. ការគ្រប់គ្រង និងថែទាំត្រី

ការចិញ្ចឹមត្រី យើងត្រូវចាប់អារម្មណ៍ទៅលើបញ្ហាមួយចំនួន ដើម្បីធានាអោយបានទិន្នផលខ្ពស់៖

### ក. ដាក់ជីអាចម៍សត្វ និងទន្រ្ទានថែគ្រប់ន្លែង

យើងត្រូវបន្ថែមជីរុក្ខជាតិស្រស់ និងជីលាមសត្វស្ងួតពី ១ ទៅ ២ ដង ក្នុង ១ ខែ តាមភាពជាក់ស្តែងនៃពណ៌ទឹកស្រះ។ បើទឹកថ្លាត្រូវដាក់ជីបន្ថែម ដើម្បីបង្កើនគុណភាពទឹកស្រះ។ បើទឹកមានពណ៌បៃតងចាស់ត្រូវបន្ថយ ឬ ផ្អាកការដាក់ជី ហើយបន្ថែមទឹកចូលស្រះ។

### ខ. កំណត់ទីកន្លែងដាក់ចំណី

មុនដាក់ចំណី គោះទឹកជាសញ្ញាអោយត្រីចំណាំពេលអោយចំណីម្តងៗ។ ផ្តល់ចំណីអោយទៀងទាត់ និងទៀងពេលធ្វើអោយត្រីចាំពេលវេលានិងទីកន្លែងដាក់ចំណី។ ការធ្វើរបៀបនេះ យើងមិនសូវបាត់បង់ចំណីទេ។ បរិមាណចំណីត្រូវដាក់អោយបានសមស្របទៅនឹងបរិមាណត្រីមានក្នុងស្រះ។ ដាក់ចំណីក្នុងកន្ត្រង ឬកញ្ច្រែងរយៈពេលពី ១ ទៅ ២ ម៉ោង មកលើកមើល បើសិនឃើញចំណីសល់ក្នុងកញ្ច្រែងគឺបន្ថយបរិមាណចំណី។



រូបភាព ៣៧ ៖ មុនពេលដាក់ចំណី យើងត្រូវគោះទឹកជាសញ្ញា ដើម្បីអោយត្រីមករកស៊ីចំណី

### គ. ការផ្តល់ចំណី

ចំណីផ្សំត្រូវស្ងោរចំអិន (កន្ទក់ ចុងអង្ករ ពោត បន្លែ ម្សៅស្លឹកគ លាយជាមួយកាកសំណល់ផ្ទះបាយ)។ ចំណែកបន្លែស្រស់ (ត្រកួន កន្ទំថេត អង្គាដី ស្លែ ស្លឹកដំឡូង) ត្រូវហាន់ និងបុកអោយម៉ត់។ ចំពោះ សារាយ ចកបាយទា ចកពងទឹក ត្រូវធ្វើស៊ុមដាក់ ។ ចំពោះកណ្តៀររៃងយកដីចេញ មុននឹងដាក់អោយត្រីស៊ី។



រូបភាព ៣៨ ៖ ស៊ុមដាក់ចំណី (ដាក់មកនៅមួយចំហៀងស្រះ)

ឃ. ផ្ដត់ផ្គង់ទឹក

ឧស្សាហ៍បន្ថែមទឹកចូលក្នុងស្រះ ពីព្រោះ កាលណាទឹកក្នុងស្រះស្រក ឬ រាក់ពេក នាំអោយទឹកក្ដៅ ដែលធ្វើអោយត្រីលូតលាស់យឺត និងងាប់ ។

ង. ត្រីពុល ឬ ត្រីងើបបណ្ដែតខ្លួនមកលើផ្ទៃទឹកច្រើន (កន្លែងចិញ្ចឹមមិនសមស្រប)

កៀវ ឬ អូសឈិប (ចលនាទឹក) ឬ បូមទឹកបន្ថែម ដើម្បីបំបែកនូវសារធាតុដែលនៅបាតស្រះ បង្កើនខ្យល់អុកស៊ីហ្សែននៅក្នុងទឹកស្រះ និងធ្វើអោយត្រីផ្លាស់ប្ដូរទឹកន្លែងក្នុងស្រះ។ បើសិនត្រីពុល (ត្រីងើបក្បាលឡើងលើផ្ទៃទឹកខ្លះទៀត ប្រកាច់លោតឡើងលើភ្លឺស្រះ) ដូច្នេះ ត្រូវបន្ថយការដាក់ជី និងផ្អាកការដាក់ចំណី ១ ឬ ២ ថ្ងៃ ហើយផ្លាស់ប្ដូរទឹកចាស់ចេញ ឬ បន្ថែមទឹកថ្មីចូល ឬក៏ធ្វើអោយទឹកក្នុងស្រះមានចលនា ដើម្បីអោយទឹកស្រះមានខ្យល់ចេញចូលពីបរិយាកាស។

ច. ដាក់ចង្កៀងលើផ្ទៃស្រះ ឬ ប្រឡាយ

ការធ្វើរបៀបនេះទាក់ទាញកូនសត្វល្អិត១ដែលមករោមអោយធ្លាក់ចូលក្នុងទឹក ហើយក្លាយជាចំណីត្រីស៊ី។

ឆ. រុក្ខជាតិដុះក្នុងស្រះ

សំអាត ឬ ដករុក្ខជាតិទឹកចេញពីក្នុងស្រះ ដូចជា រំចង់ ព្រលឹត កំប្លោក ស្មៅ ពីព្រោះ វាអាចធ្វើទឹកស្រះខ្វះពន្លឺថ្ងៃ ហើយកាលណាវាងាប់រលួយ បង្កើតជាឧស្ម័នពុល ឬ ជាតិពុលផ្សេង១ ធ្វើអោយត្រីពុល និងងាប់។



រូបភាព ៣៩ : សំអាតរុក្ខជាតិដុះក្នុងស្រះចិញ្ចឹមត្រី

ជ. ការពារត្រីចេញ

ប្រើព្រួល ឬ ស្បៃមុង ដើម្បីការពារកុំអោយត្រីផ្កក់ ពស់ អន្ទង់ ទា ចូលស៊ីកូនត្រី។ នៅពេលត្រីកាចចូល

ក្នុងស្រះ គេប្រើ អួន សន្ទូច ឬ ដាក់បង្កៃ ដើម្បីចាប់វាចេញ។ លើកភ្លឺស្រះអោយបានខ្ពស់ ការពារទឹកភ្លៀងជន់ហូរកាត់ភ្លឺស្រះ។



រូបភាព ៤០ : បង្ហូរទឹកចូលស្រះត្រោះដោយស្បៃមុងកុំអោយត្រីផ្សេងចូល



រូបភាព ៤១ : ពពួកសត្វស៊ីកូនត្រី

### ឈ. ឆែកឈើគ្របមកលើស្រះ

នៅជុំវិញមាត់ស្រះ បើមានដើមឈើធំ គប្បីកាប់មែកចេញអោយស្រឡះ ដើម្បីអោយពន្លឺថ្ងៃ និងខ្យល់ចូលបានគ្រប់គ្រាន់ ។ មិនតែប៉ុណ្ណោះ វាក៏កាត់បន្ថយបានការស្អុយទឹកដោយសារស្លឹកឈើជ្រុះចូល ។

### ញ. ដាក់រុក្ខជាតិស្រស់បង្កើតគុណភាពទឹក (ទឹកស្រះពណ៌ត្រួយចេក)

យករុក្ខជាតិស្រស់ដូចជា ទន្រ្ទានខែត្រ សណ្តែកអង្រៃ ស្លឹកអង្កាដី ។ល។ ចងជាបាច់ភ្ជាប់នឹងបង្គោលដោតក្នុងស្រះចិញ្ចឹមត្រី ។ ទន្រ្ទានខែត្រចងជាបាច់ដាក់ពន្លិចក្នុងទឹកជំរៅ ១ ទៅ ២ តឹក ពីផ្ទៃទឹក ដើម្បីអោយទទួលកំដៅថ្ងៃ វានឹងឆាប់រលួយក្លាយជាចំណីត្រី ។




រូបភាព ៤២ : ចងទន្រ្ទានខែត្រ និង សណ្តែកអង្រៃពន្លិចក្នុងទឹកស្រះ

### ដ. តាមដានការលូតលាស់របស់ត្រី

ក្រោយពីដាក់កូនត្រីចិញ្ចឹមបានរយៈពេលពី ២ ទៅ ៣ ខែ គេត្រូវត្រួតពិនិត្យមើលការលូតលាស់ និងអត្រាគង់វង្សរបស់ត្រីមាននៅក្នុងស្រះ ដើម្បីគណនាបរិមាណចំណីផ្តល់អោយត្រីស៊ីក្នុង ១ ថ្ងៃ ។ ជៀសវាងការចំណាយចំណីច្រើន និងការបាត់ចំណី (ចំណីលើស) ។ គេប្រើសំណាញ់ ឬ អួន ដើម្បីកៀរ ឬ ចាប់ត្រីវាស់ និងថ្លឹង ។



រូបភាព ៤៣ ៖ ប្រើសំណាញ់ទាញត្រី ដើម្បីត្រួតពិនិត្យការលូតលាស់របស់ត្រី

## ៨. វិធីការពារ និងព្យាបាលជំងឺត្រី

ត្រីជាសត្វរស់នៅក្នុងទឹក។ បើសិនជាត្រីមានកើតជំងឺតិចតួច យើងពិបាកក្នុងការពិនិត្យជាងសត្វរស់នៅលើគោក ដូចជា មាន់ ទា។ ដូចនេះ ដើម្បីការពារកុំអោយត្រីកើតជំងឺ យើងត្រូវតាមដានត្រីក្នុងស្រះជាប្រចាំជាពិសេសក្នុងពេលអោយចំណី និងពេលព្រឹកព្រលឹម។ ប្រសិនបើត្រីកើតជំងឺគឺមិនមែនពេលណាក៏ព្យាបាលបានទទួលជោគជ័យនោះទេ។

កត្តាមួយចំនួនដែលអាចធ្វើអោយត្រីកើតជំងឺមានដូចខាងក្រោម៖

- ទឹកស្រះខ្វះគុណភាព (ទឹកស្រះក្រខ្វក់ ឬ ស្អុយ) និងបាតស្រះសំបូរជាតិពុលក្នុងស្រះ
- លែងកូនត្រីច្រើន (ដង់ស៊ីតេខ្ពស់)
- ផ្តល់ចំណីលើស ឬ មិនគ្រប់គ្រាន់
- មិនបានសំអាតស្រះមុនដាក់ត្រីចិញ្ចឹម
- មិនបានត្រួតពិនិត្យគុណភាពកូនត្រី (សុខភាពត្រី) មុនពេលលែងចូលក្នុងស្រះ
- នៅក្នុងស្រះមិនបានសំអាតវាសំបូរទៅដោយពពួក បារ៉ាស៊ីត បាក់តេរី ពពួកផ្សិត និងវីរុស ។ល។

ដូច្នេះ ការចិញ្ចឹមត្រី ដើម្បីទប់ស្កាត់ការកើតជំងឺសំខាន់បំផុតនោះគឺ មានតែវិធីការពារ និងថែទាំទេដែលប្រសើរជាជាងការព្យាបាលជំងឺត្រី ។

### ក. ជំងឺដំបៅរលាក

ស្នាមរលាក និងដំបៅនៅលើស្បែក ស្រកា រន្ធច្រមុះ ព្រុយខ្នង ព្រុយកន្ទុយត្រី ដូចជា ឆ្ពិន អណ្តែង ផ្ទក់ កាបសាមញ្ញ។ ខ្លួនត្រីមានជាតិរំអិលពណ៌ប្រផេះក្លិនស្អុយ ត្រីរមាស់ហែលគ្មានទិសដៅ។

- ការពារ: រក្សាគុណភាពទឹកល្អជានិច្ច និងដាក់ត្រីចិញ្ចឹមនូវដង់ស៊ីតេ (ចំនួនកូនត្រី) សមស្រប
- ព្យាបាល: ចំពោះស្រះមានទំហំ ១០០ ម៉ែត្រការ៉េ យើងប្រើអំបិល (១ ទៅ ២ គីឡូក្រាម លាយជាមួយទឹក ៣០ លីត្រ) ឬ ប្រើកំបោរស ១ គីឡូក្រាម លាយជាមួយទឹក ៣០ លីត្របាចជុំវិញមាត់ស្រះ ក្នុងរយៈពេលពី ៤ ទៅ ៥ ថ្ងៃ បន្តបន្ទាប់ (១ ដង ក្នុង ១ថ្ងៃ នៅពេលព្រឹក)។



រូបភាព ៤៤ : កូនត្រីជំងឺ (មេរោគស៊ីនៅគល់កន្ទុយត្រី)

### ខ. ពពួកបារ៉ាស៊ិត

តោងជាប់នៅលើស្បែក ស្រកា ស្រកី ភ្នែក ព្រុយត្រី។ ត្រីហែលគ្មានទិសដៅ មិនស៊ីចំណី ខ្លួនត្រីហើមក្រហម និងជញ្ជក់ឈាមត្រីធ្វើអោយត្រីខ្សោយ និងងាប់ ។

- ការពារ: សំអាតស្រះអោយស្អាតមុនពេលដាក់ត្រីចិញ្ចឹម និង រក្សាទឹកអោយស្អាតជានិច្ច។
- ព្យាបាល: ចិញ្ច្រាំស្លឹកស្តៅដាក់ក្នុងថង់ក្រណាត់ (០,៥ គីឡូក្រាម ស្លឹកស្តៅក្នុង ១ ថង់)។ យើងដាក់ពី ៤ ទៅ ៦ ថង់ ក្នុងស្រះទំហំ ១០០ ម៉ែត្រការ៉េ។ ថង់ដាក់ស្លឹកស្តៅត្រូវចោះអោយមានរន្ធតូចៗ។ ចង ថង់ស្លឹកស្តៅភ្ជាប់នឹងស៊ុមដាក់ចំណី រយៈពេលពី ៤ ទៅ ៥ ថ្ងៃ បន្តបន្ទាប់(៣ថ្ងៃ ប្តូរថង់ចេញម្តង)។



រូបភាព ៤៥ : សត្វយុផ្កា



រូបភាព ៤៦ : សត្វចៃត្រី

## ៩. ការប្រមូលផលត្រី

គេប្រមូលផលត្រីចិញ្ចឹមនៅចុងរដូវវស្សា និងដើមរដូវប្រាំង ពីព្រោះ នៅពេលនោះទឹកស្រះ ឬ ប្រឡាយចាប់ផ្ដើមរីង ឬ រាក់ ហើយគ្មានប្រភពទឹកសំរាប់ផ្គង់ផ្គង់បន្ថែម។ ដើម្បីប្រមូលផលត្រីបានទាំងត្រីចិញ្ចឹមផង និងត្រីស្រែផង គឺនៅចុងរដូវវស្សា (កត្តិក-មិគសិរ) គេបើករង្វះអោយទឹកស្រែហូរចូលស្រះ ឬ ប្រឡាយ ដើម្បីអោយត្រីស្រែចូលមករស់នៅ និងបង្កើនបរិមាណទឹកស្រះបន្ថែម។ បើតំបន់មានប្រភពទឹកបញ្ចេញបញ្ចូល ហើយអាចផ្គត់ផ្គង់បានគ្រប់រដូវ គេអាចប្រមូលផលត្រីដោយចាប់រំលោះត្រី (អូសចាប់ត្រីធំ) និងទុកត្រីតូចចិញ្ចឹមបន្ត ដើម្បីអោយផ្ទៃរស់នៅរបស់ត្រីទូលាយចំពោះត្រីនៅសល់ក្នុងស្រះវាលូតលាស់បន្ត ។ បើសិនតំលៃត្រីទីផ្សារខ្ពស់គឺចាប់លក់។



រូបភាព ៤៧ : ប្រមូលយកត្រីធំ និង បំប៉នត្រីតូចបន្ត

ក្រោយពីប្រមូលផលត្រីចិញ្ចឹមរួច គេត្រូវរៀបចំស្រះឡើងវិញ ដូចជា ជួសជុលទំនប់ ឬ ភ្លឺស្រះសំអាតកាកសំណល់នៅបាតស្រះ កាត់មែកឈើនៅជុំវិញស្រះយកចេញ ដើម្បីត្រៀមដាក់ត្រីចិញ្ចឹមបន្តទៀត។



រូបភាព ៤៨ : ការប្រមូលផលត្រី

## ១០. បទពិសោធន៍សំខាន់ៗ របស់កសិករក្នុងការចិញ្ចឹមត្រី

### ១០.១ បទពិសោធន៍កសិករ ចាន់ សុធា

លោក ចាន់ សុធា ជាកសិកររស់នៅភូមិទីប៉ាត់ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់មាន បទពិសោធន៍ក្នុងការចិញ្ចឹមត្រីតាមបច្ចេកទេស ។ នៅក្នុងស្រះដែលមានផ្ទៃ ៣២០ ម៉ែត្រការ៉េ និងជំរៅ ២.៥ ម៉ែត្រ ហើយមានប្រព័ន្ធប្រឡាយជុំវិញភ្ជាប់ទៅនឹងស្រះ ។ គាត់ទទួលផលត្រីចិញ្ចឹមបានចំនួន ៣០០ គីឡូក្រាម និងត្រីស្រែ ចូលមកនៅ១៤ គីឡូក្រាម ។ បទពិសោធន៍ដែលទទួលបានផលខ្ពស់របស់គាត់បង្ហាញជូនដូចខាងក្រោមៈ

**ក. ការរៀបចំស្រះ**

- ស្តារភក់បាតស្រះ និង លើកភ្លឺខ្ពស់ព័ន្ធជុំវិញស្រែ និងជីកប្រព័ន្ធប្រឡាយភ្ជាប់នឹងស្រះ
- បាចកំបោរស ១៥ គីឡូក្រាម និងហាលពន្លឺថ្ងៃបាតស្រះ ចំនួន ៣ ថ្ងៃ ។

**ខ. បង្កើតចំណីធម្មជាតិ**

- ដាក់អាចម៍គោស្ងួត ៥០ គីឡូក្រាម និងទន្រ្ទានខែត្រ (ចងជាបាច់) ៤០ គីឡូក្រាម ។
- រក្សាចំណីធម្មជាតិ ដាក់បន្ថែមអាចម៍គោស្ងួត ១០ ទៅ ១៥ គ.ក្រ និង ទន្រ្ទានខែត្រ ១០ ទៅ ២០ គ.ក្រ រយៈពេល ពី ២០ ទៅ ២៥ ថ្ងៃ ដាក់ម្តង។

**គ. លែងកូនត្រី**

- ក្រោយពីបានបង្កើតចំណីធម្មជាតិ ១ អាទិត្យទើបគាត់លែងកូនត្រី
- ចិញ្ចឹមចំរុះ រួមមាន ត្រីឆ្ពិន កាបស កាបឥណ្ឌា កន្ធរ ប្រា ទីឡាព្យ៉ា និងកាបសាមញ្ញ
- លែងកូនសរុបកូនត្រីចំនួន ១.០០០ ក្បាល ។ គាត់ត្រាំថង់កូនត្រី ១៥ នាទី ក្នុងស្រះ មុននឹងលែង កូនត្រីចេញពីថង់ចូលស្រះ ។

**ឃ. ការផ្តល់ចំណី**

- ចំណីត្រី ដូចជា កន្ទក់ ចុងអង្ករ ចកបាយទា ត្រកួន កណ្តៀរ កាកសំណល់ផ្ទះបាយ និងចំណីកែច្នៃ
- អោយស៊ី ១ ថ្ងៃ ពី ២ ទៅ៣ ដង ជាពិសេស (ព្រឹក និងល្ងាច) ។ បរិមាណចំណីគាត់អោយ ស៊ីទៅតាមការលូតលាស់របស់ត្រី ។

**ង. ការគ្រប់គ្រង និងថែទាំ**

- ការពារសត្វមកបំផ្លាញពេលកូនត្រីនៅតូច និងលើកភ្លឺខ្ពស់ការពារត្រីចេញ
- ផ្តល់ចំណីរៀងរាល់ថ្ងៃ ជាពិសេសផ្តល់ចំណីទៅការលូតលាស់ (កើនទំងន់)
- សំអាតស្មៅជុំវិញស្រះ និងបង្កើតចំណីធម្មជាតិ (ទឹកពណ៌បៃតងខ្ចី) តាមរយៈដាក់ជីបន្ថែម

**ច. រយៈពេលចិញ្ចឹមៈ** ៧ ខែ ។

### ១០.២ បទពិសោធន៍កសិករ កែវ ប៊ុន

លោក កែវ ប៊ុន ជាកសិកររស់នៅភូមិទីប៉ាត់ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់មានបទពិសោធន៍ល្អៗច្រើនក្នុងការចិញ្ចឹមត្រី។ នៅលើក្រលាផ្ទៃស្រះ ៣០០ ម៉ែត្រការ៉េ និងជំរៅ ២ ម៉ែត្រ គាត់ទទួលផលត្រីចិញ្ចឹមបាន ១៦៥ គីឡូក្រាម និងត្រីស្រែចូលមកនៅ ២០ គីឡូក្រាម។ បទពិសោធន៍ចិញ្ចឹមត្រីរបស់គាត់បង្ហាញដូចខាងក្រោមៈ

**ក. ការរៀបចំស្រះ**

- ស្តារភក់បាតស្រះ (ទុកភក់កំរាស់ ១ ទៅ ២ តឹក) និង ជួសជុលភ្លឺជុំវិញស្រះ
- បាចកំបោរស ១៤ គីឡូក្រាម និងហាលពន្លឺថ្ងៃបាតស្រះចំនួន ៧ ថ្ងៃ ។

**ខ. បង្កើតចំណីធម្មជាតិ**

- ដាក់អាចម៍គោស្ងួត ៣៥ គីឡូក្រាម និងទន្រ្ទានខៃត្រស្រស់ ២០ គីឡូក្រាម
- បន្ថែមជីស្រស់ ៤ ទៅ ៥ គីឡូក្រាម និង អាចម៍គោស្ងួត ២៥ គីឡូក្រាម (១០ ទៅ ១៥ថ្ងៃ ថែមម្តង) ។

**គ. ចំនួនកូនត្រីដាក់ចិញ្ចឹម**

- ប្រភេទត្រីប្រា កន្ធរ ទីឡាព្យ៉ា អណ្តែង
- សរុបកូនត្រី ១៤០០ ក្បាល ។

**ឃ. ការផ្តល់ចំណី**

- ប្រភេទចំណី ដូចជា កន្ទក់ ចុងអង្ករ ជន្លេន កណ្តៀវ ចកបាយទា កាកសំណល់ផ្ទះបាយ និងត្រកួន
- ១ ខែ ដំបូងអោយស៊ី ២ គីឡូក្រាម ក្នុង ១ ថ្ងៃ (១ ដង ក្នុង ១ ថ្ងៃ)
- ២ ខែបន្តមកទៀត អោយស៊ី ៣ គីឡូក្រាម ក្នុង ១ ថ្ងៃ ដោយចែកជា ២ ពេល (ព្រឹក និងល្ងាច) និងថែមចកបាយទា ១ ធុងបេត្រូ (១៣ គ.ក្រ) ក្នុង ១ ថ្ងៃ។

**ង. ការគ្រប់គ្រង និងថែទាំ**

- ការពារសត្វមកបំផ្លាញពេលកូនត្រីនៅតូច
- ផ្តល់ចំណីរៀងរាល់ថ្ងៃ និង ទៀងទាត់
- កាត់មែកឈើដែលធ្លាក់មកលើស្រះចេញ
- ដាក់ជីបង្កើតចំណីធម្មជាតិទៀងទាត់
- រក្សាទឹកស្រះមានប្លង់តុង (ទឹកពណ៌បៃតងខ្ចី) ។

**ច. រយៈពេលចិញ្ចឹមៈ** ៧ ខែ ។

## ១០.៣ បទពិសោធន៍កសិករ សុខ ទិត្យ

លោក សុខ ទិត្យ ជាកសិកររស់នៅភូមិ អង្គក្លួច ឃុំព្រះបន្ទា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ គាត់មានបទពិសោធន៍ល្អៗច្រើនក្នុងការចិញ្ចឹមត្រី។ ស្រះចិញ្ចឹមត្រីរបស់គាត់មានក្រលាផ្ទៃ ៣២៥ ម៉ែត្រការ៉េ ជំរៅ ២ ម៉ែត្រ និងភ្ជាប់ទៅប្រឡាយបណ្តោយ ១១០ ម៉ែត្រ ទទឹង ២ ម៉ែត្រ ជំរៅ ០,៧ ម៉ែត្រ។ គាត់ទទួលផលត្រីចិញ្ចឹមបាន ៣០៨ គីឡូក្រាម និងនៅចុងរដូវវស្សាគាត់បើករង្វះទឹកអោយត្រីស្រែ ហើយទទួលផលត្រីចំនួន ១០ គីឡូក្រាម។ បទពិសោធន៍ចិញ្ចឹមរបស់គាត់បង្ហាញ ដូចខាងក្រោមះ

### ក. ការរៀបចំស្រះ

- ស្តារភក់បាតស្រះ និង លើកភ្លឺស្រះ ជាពិសេសជីកប្រឡាយភ្ជាប់ទៅនឹងស្រះ
- បាចកំបោរសនៅបាតស្រះចំនួន ១៥ គីឡូក្រាម
- ហាលពន្លឺថ្ងៃចោលចំនួន ៥ ថ្ងៃ ។

### ខ. បង្កើតចំណីធម្មជាតិ

- ដាក់អាចម៍គោស្ងួត ៣ អំរែក ( ប្រហែល ១៥ គីឡូក្រាម ក្នុង ១ អំរែក)
- ទន្រ្ទានខៃត្រស្រស់ ៥ បាច់ ( ប្រហែល ១០ គីឡូក្រាម ក្នុង ១ បាច់)
- បន្ថែមជីស្រស់ ៤ គីឡូក្រាម និង អាចម៍គោស្ងួត ១០ គីឡូក្រាម ( ១០ ទៅ ១៥ថ្ងៃ ថែមម្តង) ។

### គ. ចំនួនកូនត្រីដាក់ចិញ្ចឹម

- ប្រភេទត្រីឆ្ពិន ប្រា កាបស កាបឥណ្ឌា កាបសាមញ្ញ ។
- សរុបកូនត្រី ៨៥០ ក្បាល ។

### ឃ. ការផ្តល់ចំណី

- ប្រភេទចំណី ដូចជា កន្ទក់ កណ្ដៀវ ចកបាយទា កាកសំណល់ផ្ទះបាយ និងត្រកួន
- ១ ខែ ដំបូងអោយស៊ី ២ គីឡូក្រាម ក្នុង ១ ថ្ងៃ និង ២ខែបន្តមកទៀត
- ផ្តល់ចំណី ៣ គីឡូក្រាម ក្នុង ១ ថ្ងៃ ដោយចែកជា ២ ពេល ( ព្រឹក និងល្ងាច) ។

### ង. ការគ្រប់គ្រង និងថែទាំ

- ការពារសត្វមកបំផ្លាញពេលកូនត្រីនៅតូច ( ប្រើស្បៃមុងព័ទ្ធជុំវិញស្រះ)
- ផ្តល់ចំណីរៀងរាល់ថ្ងៃ និង សំអាតស្មៅជុំវិញស្រះ
- បន្ថែមជីអាចម៍ក្របីស្ងួត និង ទន្រ្ទានខៃត្រ រៀងរាល់ខែ (១ ខែម្តង) ។

### ច. រយៈពេលចិញ្ចឹមះ ៩ ខែ ។

### ១០.៤ បទពិសោធន៍កសិករ សយ សុធា

លោក សយ សុធា ជាកសិករនៅភូមិចមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ។ គាត់មានបទពិសោធន៍ចិញ្ចឹមត្រីក្នុងស្រះ។ ស្រះរបស់គាត់មានទំហំ ១០០ ម៉ែត្រការ៉េ និងជីកប្រឡាយ ៥០ ម៉ែត្រ ។ គាត់ទទួលផលត្រីបានជាង ៧០ គីឡូក្រាម (កូនត្រីដាក់ចិញ្ចឹមចំនួន ១២០០ ក្បាល)។ បទពិសោធន៍ដែលគាត់ទទួលបានទិន្នផលខ្ពស់នេះ បង្ហាញដូចខាងក្រោម :

#### ក. ទីតាំងស្រះ

ស្រះនៅក្បែរផ្ទះ និងស្រះចិញ្ចឹមភ្ជាប់ទៅប្រឡាយដែលនៅក្នុងស្រែ។

#### ខ. ការរៀបចំស្រះ

គាត់លើកភ្លឺខ្ពស់ព័ទ្ធជុំវិញស្រះមានស្ពាភក់បាតស្រះ និងមានជីក ប្រព័ន្ធប្រឡាយអោយត្រីចេញចូលពីស្រះប្រឡាយ ។

#### គ. កូនត្រីដាក់ចិញ្ចឹម

មុនពេលលែងកូនត្រី គាត់បានបង្កើតចំណីធម្មជាតិជាមុនសិន។ ជីកយកកូនត្រីមកដល់ផ្ទះ គាត់ដាក់ថង់កូនត្រីត្រាំក្នុងទឹកស្រះប្រហែលជាង ១៥ នាទី ទើបគាត់លែងកូនត្រីចូលក្នុងស្រះ។ ប្រភេទត្រីដែលបានដាក់ចិញ្ចឹមរួមមាន ត្រីឆ្ពិន កាបឥណ្ឌា កាបសាមញ្ញ។ ចំនួនកូនត្រីសរុប ១២០០ ក្បាល។

#### ឃ. ការផ្តល់ចំណី

ចំណីមានសារៈសំខាន់ជាខ្លាំងក្នុងការចិញ្ចឹមត្រី ដើម្បីអោយត្រីឆាប់លូតលាស់។ គាត់បានដាក់ចំណីអោយត្រី ដូចជា កន្ទក់ ចុងអង្ករ ត្រកួន ចកបាយទា និងកាកសំណល់ផ្ទះបាយ។

#### ង. ការគ្រប់គ្រង និងថែរក្សា

- ការពារមនុស្សឆក់ និងស្ទូច ដាក់មង
- ការពារសត្វបំផ្លាញពេលកូនត្រីនៅតូច
- ផ្តល់ចំណីជារៀងរាល់ថ្ងៃ
- ថែទឹកអោយមានពណ៌បៃតង មើលភ្លឺស្រះមិនអោយទឹកជំនន់ហូរចូលពេលភ្លៀងខ្លាំងម្តងៗ ។

#### ច. រយៈពេលចិញ្ចឹម :

ក្រោយពីបានដាក់ត្រីចិញ្ចឹមរហូតដល់ប្រមូលផលគឺមានរយៈពេល ៧ ខែ។

## ១១. ការសរុបនូវចំណុចសំខាន់ៗ និង សំណូមពរមួយចំនួនដល់អ្នកចិញ្ចឹមត្រី

សរុបមកដើម្បីអោយយើងចិញ្ចឹមត្រីបានផលខ្ពស់ គួរអនុវត្តន៍តាមចំណុចសំខាន់ដូចខាងក្រោម :

- ☞ រៀបចំសំអាតស្រះដូចជា បាចកំបោរស ហាលពន្លឺថ្ងៃ ដាក់ជីទ្រាប់បាតស្រះ លើកទំនប់ខ្ពស់ និងមាំ
- ☞ មុនពេលដាក់ត្រីចិញ្ចឹមចូលស្រះ ត្រូវបង្កើតចំណីធម្មជាតិ ( ទឹកពណ៌បៃតង ) ជាមុនសិន
- ☞ ដាក់ត្រីចិញ្ចឹមនៅដើមរដូវវស្សា ពីព្រោះ រយៈពេលចិញ្ចឹមបានយូរ និងពពួកសត្រូវមានតិចតួច
- ☞ មុនពេលលែងត្រូវត្រាំថង់កូនត្រីក្នុងទឹកស្រះរយៈពេល ១៥ នាទី និងដឹកជញ្ជូននៅពេលព្រឹក និង ល្ងាច
- ☞ ធ្វើរបាំងការពាជុំវិញស្រះ ការពារពពួកសត្វស៊ីកូនត្រី ដូចជា ត្រីកាច ពស់ អន្ទង ទា... ។ល ។
- ☞ កុំដាក់ចំណីអោយស៊ីនៅថ្ងៃលែងដំបូង ពីព្រោះ ត្រីឃ្លានចំណីស៊ីច្រើនបណ្តាលអោយឆ្អែតងាប់
- ☞ កូនត្រីចិញ្ចឹម មានប្រវែងដងខ្លួនពី ៤ ទៅ ៦ ហ៊ុន ឬ ៨ ហ៊ុន ( កូនត្រីធំអត្រារស់ខ្ពស់)
- ☞ ចំនួនកូនត្រីលែងចូលស្រះ ៣-៤ ក្បាល ក្នុង ១ ម៉ែត្រការ៉េ
- ☞ រក្សាជំរៅទឹកស្រះរាក់បំផុត គឺ ១.៥ ម៉ែត្រ និង ជ្រៅបំផុត ៣ ម៉ែត្រ
- ☞ ផ្តល់ចំណីអោយស៊ីទៀងទាត់ពេល និងកំណត់ទីកន្លែងផ្តល់ចំណីអោយត្រីស្គាល់
- ☞ ស្រះទទួលបានពន្លឺថ្ងៃគ្រប់គ្រាន់ និងគ្មានដើមឈើធំៗ នៅក្បែរស្រះចិញ្ចឹមត្រី
- ☞ ប្តូរទឹកស្រះចិញ្ចឹមត្រីពី ៣០ ទៅ ៤០ ភាគរយ នៃចំណុះទឹកក្នុងស្រះ ( ពេលទឹកគ្មានគុណភាព)
- ☞ សំអាតស្មៅ ឬ រុក្ខជាតិដុះក្នុងស្រះ និងជុំវិញមាត់ស្រះចិញ្ចឹមត្រី
- ☞ ដើរត្រួតពិនិត្យតាមមាត់ស្រះពេលព្រឹកព្រលឹម ដើម្បីសង្កេតសកម្មភាពត្រី ឬ ត្រីពុល ។

### ដូចគ្នាដែរ ដើម្បីចិញ្ចឹមត្រីអោយបានផលខ្ពស់ យើងត្រូវជៀសវាងនូវចំនុចមួយចំនួនដូចខាងក្រោម:

- ✓ កុំលែងកូនត្រីពេលកំពុងភ្លៀង ពីព្រោះ ទឹកភ្លៀងមានជាតិអាស៊ីតធ្វើអោយត្រីងាប់ ឬ ពុល
- ✓ ពេលត្រីពុលត្រូវផ្អាកការដាក់ជី ឬ ផ្តល់ចំណីពី ១ ទៅ ២ ថ្ងៃ
- ✓ កុំបើករង្វះមាត់ស្រះមុនពេលដាក់កូនត្រីចិញ្ចឹម ពីព្រោះ ត្រីកាចចូលមកក្នុងស្រះ ( វាស៊ីកូនត្រី)
- ✓ ដឹកកូនត្រីផ្លូវឆ្ងាយត្រូវបញ្ចូលខ្យល់អុកស៊ីហ្សែន ( មិនអោយលើសពី ៣ ទៅ ៤ ម៉ោង)
- ✓ ត្រូវបង្អឹកកូនត្រី និងកៀរកូនត្រីមកដាក់ក្នុងហាប៉ារយៈពេល ២៤ម៉ោង សិន ។
- ✓ មុនថ្ងៃកៀរប្រមូលផលត្រី ត្រូវផ្អាកការអោយចំណី ១ ឬ ២ ថ្ងៃ ដើម្បីកៀរកុំអោយងាប់ត្រី
- ✓ ជៀសវាងការប្រើថ្នាំពុល ដីឌីធី និង ឧបករណ៍ឆក់ក្នុងការចាប់ត្រី ឬ ប្រមូលផលត្រីក្នុងស្រះ
- ✓ ជៀសវាងកៀរត្រីពេលមេឃក្តៅ ពីព្រោះ ទឹកក្នុងស្រះក្តៅធ្វើអោយត្រីរលាកស្រកា ឬ ស្រកីត្រី
- ✓ ជៀសវាងកៀរ ក្រោយពេលដាក់ចំណីភ្លាម ។ ជៀសវាងត្រាំស្លឹក ឬ លាងធុងបាញ់ថ្នាំពុលក្នុងស្រះ ។



▶ ត្រីកាបស (Silver carp)



▶ ត្រីកាបក្បាលធំ (Bighead carp)



▶ ត្រីកាបសាមញ្ញ (Common carp)



▶ ត្រីឃឿងក្រឃេម (Kissing gouramy)



▶ ត្រីកាបឥណ្ឌា (India carp)



▶ ត្រីឆ្ពិន (Silver barb)



▶ ត្រីកន្ធរ (Snakeskin gourami)



▶ ត្រីអណ្ដែង (Catfish)



▶ ត្រីទីឡាព្យា (Tilapia)



▶ ត្រីប្រា (Iridescent shark-catfish)

## យើងចិញ្ចឹមត្រី ដើម្បីជីវភាពប្រចាំថ្ងៃ និងមិនចំណាយលុយទិញត្រី សូមសាកល្បងតាមការណែនាំពីរបៀបចិញ្ចឹមត្រីទាំង ១៤ ចំនុច ដូចខាងក្រោមនេះ

១. ជីកស្រះមិនលិចទឹកនៅរដូវវស្សា គ្មានម្លប់ឈើគ្របពីលើស្រះ និងមានទំនប់ខ្ពស់ការពារត្រីចេញ។

១៤. បើត្រីពុលផ្កាកអោយចំណី (១ ឬ ២ ថ្ងៃ) និងផ្អាកការដាក់ជី។ បន្ថែមទឹកថ្មីចូលស្រះ និងសំអាតរុក្ខជាតិដុះក្នុងស្រះ។

១៣. ពេលព្រឹកទឹកស្រះខ្វះខ្យល់អុកស៊ីហ្សែន ធ្វើឱ្យត្រីងើបក្បាល ចាំត្រីមុជ ទៅក្រោមវិញ ទើបដាក់ចំណីឱ្យស៊ី។ បន្ថែមទឹកថ្មីចូលស្រះចិញ្ចឹមត្រី។

១២. ការពារថ្នាំសំលាប់សត្វល្អិត ហូរចូលស្រះចិញ្ចឹមត្រី។ លើកភ្លឺស្រះខ្ពស់ ដើម្បីការពារត្រីចេញ។ បើទឹកហូរកាត់ស្រះ ត្រីចេញអស់។

២. ចិញ្ចឹមត្រីក្នុងស្រះភ្ជាប់ទៅប្រឡាយឬ ស្រែ (ត្រីឆាប់ធំ)។

១១. ចំណីផ្សំ: កន្ទក់ ចុងអង្ករ ត្រកួន អង្កាដីដំឡូង និងម្សៅត្រី (ចំរិន)។ ចំណីបន្ថែម:សារាយ ចកបាយទា កណ្តៀរ...

៣. ផ្ទៃស្រះមានទំហំចាប់ពី ១០០ ម៉ែត្រ ឡើងទៅ និងជំរៅពី ១,៥ ទៅ ៣ ម៉ែត្រ។

១០. បរិមាណចំណី: អោយស៊ី ២ ដងក្នុង ១ថ្ងៃ (ព្រឹកនិងល្ងាច)។ អោយស៊ី ៣ ភាគរយនៃទំងន់ខ្លួនត្រីសរុបក្នុងស្រះ។ ផ្តល់ចំណីអោយបានទៀងទាត់ និងគ្រប់គ្រាន់ (ត្រីឆាប់ធំ)។

៤. សំអាតរុក្ខជាតិជុំវិញស្រះ យកសំរាមចេញ ទុកភក់នៅបាតស្រះពី ២ ទៅ ៣ តឹក។

៩. ចំនួនកូនត្រីលែង: កូនត្រី ៣ ក្បាល ក្នុង ១ ម៉ែត្រការ៉េ នៃផ្ទៃស្រះ។ ត្រាំថង់កូនត្រី ២០ នាទី ក្នុងទឹកស្រះ ដើម្បីអោយកំដៅទឹកក្នុងថង់កូនត្រី និងទឹកស្រះប្រហាក់ប្រហែលគ្នា។

៥. បាចកំបោរសពី ១០ ទៅ១៥ គ.ក្រ (ស្រះថ្មី)ក្នុងស្រះ១០០ម² និងស្រះចាស់ប្រើតិចជាង។



៦. ហាលថ្ងៃបាតស្រះតិចបំផុត ៣ ថ្ងៃ និងកុំអោយទឹកពីខាងក្រៅហូរចូលស្រះ។

៧. ប្រើស្បៃនីឡុងព័ទ្ធជុំវិញស្រះការពារពពួកសត្វស៊ីកូនត្រី: ត្រីផ្ទក់ ត្រីអណ្តែង ពស់ អន្ទង់ កង្កែប ទា.........
បើមិនធ្វើតាមរបៀបនេះទេត្រីរបស់អ្នកនឹងបាត់ច្រើន ។

៨. ត្រាំអាចម៍គោ ឬក្របី ស្ងួត ៦០គ.ក្រ និងទន្រ្ទានខែត្រស្រស់ ៤០ គ.ក្រ ដាក់ក្នុងរណ្តៅរួចបង្ហូរចូលស្រះទំហំ ១០០ម²។ បង្ហូរទឹកជីដែលរលួយ ចូលទៅក្នុងស្រះ ក្រោយមកឃើញទឹកស្រះឡើងពណ៌ត្រួយចេក ទើបយើងលែងកូនត្រីចូលស្រះ។



ចិញ្ច្រាំបន្លែអោយត្រីស៊ី



ដាក់ជីលាមកសត្វទ្រាប់បាតប្រឡាយ



របៀបលែងកូនត្រី



សកម្មភាពត្រីស៊ីចំណីចំរុះ



ពិនិត្យចំណី និងបរិមាណត្រី



ជុំធ្ន្រានខែត្រចងពន្លិចដាក់ក្នុងស្រះ



សំអាតរុក្ខជាតិដុះក្នុងស្រះចិញ្ចឹមត្រី



បញ្ចូលទឹកក្នុងស្រះច្រោះដោយស្បៃមុង